វេទិកានៃអង្គការក្រៅរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីការប្រែសើរឡើង
Working Together for Positive Change

ការវិភាគស្ថិតិស្តីពីវិវាទដីធ្លីនៅកម្ពុជា ឆ្នាំ ២០១៦



ភ្នំពេញ, កម្ពុជា
ខែ មិថុនា ឆ្នាំ ២០១៧
ការបោះពុម្ពជាភាសាខ្មែរ និងអង់គ្លេស

ការវិភាគស្ថិតិស្តីពីវិវាទដីធ្លីនៅកម្ពុជាឆ្នាំ ២០១៦

កាលបរិច្ឆេទបោះពុម្ពផ្សាយ៖ ខែមិថុនា ឆ្នាំ ២០១៧
បោះពុម្ពផ្សាយដោយ៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
អ្នកសរសេរដោយ៖ មជ្ឈមណ្ឌលស្រាវជ្រាវ តស៊ូមតិ និងទំនាក់ទំនង
វិភាគទិន្នន័យដោយ៖ លោកស្រី នេត ចណ្ណា មន្ត្រីគ្រប់គ្រងព័ត៌មានភូមិសាស្ត្រ និងទិន្នន័យ
រចនាអត្ថបទដោយ៖ លោក ភួន ឃូ អ្នកសម្របសម្រួលសារព័ត៌មាន និងទំនាក់ទំនង

អាសយដ្ឋាន៖ លេខ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន
រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ៖ ២២៩៥, រាជធានីភ្នំពេញ-៣
ទូរស័ព្ទ៖ (៨៥៥-២៣) ២១៤ ៤២៩
ទូរសារ៖ (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល៖ ngoforum@ngoforum.org.kh
គេហទំព័រ៖ www.ngoforum.org.kh

សេចក្តីបញ្ជាក់៖

ទស្សនៈបង្ហាញក្នុងរបាយការណ៍នេះសុទ្ធតែជាទស្សនៈរបស់អ្នកនិពន្ធ ហើយមិនបង្ហាញពីទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាទេ។ នៅពេលខ្លឹមសារនៃរបាយការណ៍នេះត្រូវគេដកស្រង់ ឬផលិតសារជាថ្មី ការទទួលស្គាល់ និងការសុំអនុញ្ញាតសិទ្ធិរបស់អ្នកនិពន្ធ និងអ្នកបោះពុម្ពផ្សាយនឹងត្រូវគេអោយតម្លៃ។

© **វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា, ខែមិថុនា ឆ្នាំ ២០១៧**

សេចក្តីថ្លែងអំណរគុណ

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះបុគ្គលិកនិងអង្គការសង្គមស៊ីវិលទាំងអស់ ដែលបានជួយផ្តល់ព័ត៌មានក្នុងការចងក្រងទិន្នន័យសម្រាប់បង្ហាញជូនក្នុងរបាយការណ៍នេះ។ យើងខ្ញុំសូមអរគុណជាពិសេស ចំពោះសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅ កម្ពុជា (ADHOC) សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស(LICADHO) អង្គការរក្សា ការពារសិទ្ធិមនុស្សនៃកម្ពុជា(Vigilance) សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍(KKKHRDA) ក្រុមការងារពិសេសសិទ្ធិលំនៅឋាន(HRTF) អង្គការស្រាវជ្រាវជាតិកម្ពុជា(CNRO) អង្គការអនុផលព្រៃឈើ(NTFP) អង្គការស៊ីស៊ីឌី(CCD) និងសមាជិកបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន(LAHRiN) ក៏ដូចជា អាជ្ញាធរថ្នាក់ខេត្តទាំងអស់ ដែលបានផ្តល់ការគាំទ្រក្នុងអំឡុងពេលប្រមូលនិងផ្ទៀងផ្ទាត់ទិន្នន័យនៅមូលដ្ឋាន។ ផ្នែកស្រាវជ្រាវនិងទិន្នន័យរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា សូមអរគុណចំពោះបណ្តាញអង្គការសង្គមស៊ីវិល និងតំណាងសហគមន៍ទាំងឡាយដែលបានផ្តល់ព័ត៌មាន។ របាយការណ៍នេះ មិនអាចសម្រេចបានទេបើគ្មានការជួយជ្រោមជ្រែង និងគាំទ្រពីសំណាក់លោក/លោកស្រី។

មាតិកា

អក្សរកាត់ ii
និយមន័យនៃបច្ចេកសព្ទ iv
១. សេចក្តីផ្តើម ១
២. គោលបំណងនៃរបាយការណ៍ ៣
៣. វិធីសាស្ត្រ ៤
៣.១ លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ករណីវិវាទដីធ្លី ៤
៣.២ ការប្រមូលទិន្នន័យ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីពីវិវាទដីធ្លី ៥
៣.៣ ឧបករណ៍ប្រើប្រាស់ក្នុងការវិភាគស្ថិតិ ៧
៤. យន្តការដោះស្រាយវិវាទ ៨
៥. លទ្ធផលនៃការវិភាគទិន្នន័យ ១២
៥.១ វិវាទដីធ្លីគិតតាមឆ្នាំ ១២
៥.២ ទីតាំងនៃវិវាទ ១៥
៥.២.១ វិវាទដីធ្លីក្នុងខេត្តរតនគិរី ១៦
៥.២.២ វិវាទដីធ្លីក្នុងរាជធានីភ្នំពេញ ១៨
៦. វិវាទដីធ្លីដែលបានដោះស្រាយ គិតតាមឆ្នាំ ២០
៦.១ ស្ថាប័នទទួលពាក្យបណ្តឹង ២៤
៦.២ ដំណើរការដោះស្រាយ ២៥
៦.៣ ស្ថាប័នដោះស្រាយវិវាទដីធ្លីក្នុងឆ្នាំ២០១៦ ..... ២៩
៧. ត្រួសារទេផលប៉ះពាល់ពីវិវាទដីធ្លី ៣២
៧.១ ប្រភេទដីដែលរងផលប៉ះពាល់ពីវិវាទដីធ្លី ៣៥
៧.២ មូលហេតុនៃទំនាស់ដីធ្លី ៣៧
៨. ឯកសារប្រើប្រាស់ដោយតាគីវិវាទក្នុងការទទួលបានដី ៤២
៩. ការគាំទ្រាប់បច្ចុប្បន្នលើដីមានវិវាទ ៤៦
១០. វិវាទដីធ្លីដែលបង្ករផលប៉ះពាល់លើជនជាតិដើមតាគតិច ៤៨
១១. ការផ្លាស់ទីកន្លែងដោយបង្ខំ ៥២
១២. បទពិសោធន៍នៃដំណោះស្រាយល្អៗ ៥៥
១៣. សន្និបាត ៥៦
ឧបសម្ព័ន្ធ ៦១

អក្សរកាត់

ADHOC	សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា
CEPA	សមាគមថែរក្សាបរិស្ថាន និង វប្បធម៌
CF	សហគមន៍ព្រៃឈើ
CLEC	មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍
CNRO	អង្គការស្រាវជ្រាវជាតិកម្ពុជា
EIA	ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
ELC	សម្បទានដីសេដ្ឋកិច្ច
FA	រដ្ឋបាលព្រៃឈើ
GIS	ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ
GIZ	សហគ្រាសសហព័ន្ធអាឡឺម៉ង់សម្រាប់សម្រាប់សហប្រត្តិការអន្តរជាតិ (GIZ) BmbH
Ha	ហិកតា
HH	គ្រួសារ
IMR	សិទ្ធិរបស់ជនជាតិដើមភាគតិច
IP	ជនជាតិដើមភាគតិច
KKKHRDA	សមាគមសិទ្ធិមនុស្សដើម្បីអភិវឌ្ឍន៍ខ្មែរកម្ពុជា
LC	សម្បទានដី
LD	វិវាទដីធ្លី
LICADHO	សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស លីកាដូ
MAFF	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
MoE	ក្រសួងបរិស្ថាន
NALDR	អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
NGOF	វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
RAC	មជ្ឈមណ្ឌលស្រាវជ្រាវ តស៊ូមតិ និងទំនាក់ទំនង
RFA	វិទ្យុអាស៊ីសេរី

RGC	រាជរដ្ឋាភិបាលកម្ពុជា
SLC	សម្បទានដីសង្គមកិច្ច
Vigilance	អង្គការឃ្លាំមើលសិទ្ធមនុស្សកម្ពុជា

និយមន័យនៃបច្ចេកសព្ទ

សម្រាប់គោលបំណងនៃរបាយការណ៍នេះ បច្ចេកសព្ទខាងក្រោម ត្រូវបានប្រើសម្រាប់តែរបាយការណ៍នេះប៉ុណ្ណោះ ដូច្នេះអ្នកប្រើប្រាស់គប្បីប្រយ័ត្នប្រយែងក្នុងការប្រើបច្ចេកសព្ទទាំងនេះក្នុងស្ថានភាពដទៃ។

- **ការបោះបង់ពាក្យបណ្តឹង៖** សំដៅលើករណីទាំងឡាយ ដែលបណ្តឹងទាមទារដីត្រូវបានបោះបង់ចោល ឬរំលត់ដោយភាគីដើមបណ្តឹង។
- **ដីកសិកម្ម៖** ដីដែលមានលក្ខណៈសមស្របសម្រាប់ផលិតកម្មកសិកម្មរួមមានដំណាំ និងបសុសត្វ (កន្លែងចិញ្ចឹមសត្វ)។
- **ការផ្លាស់ទីកន្លែងដោយបង្ខំ៖** ការបង្ខំប្រជាជនឱ្យចាកចេញ ពីដីដែលពួកគាត់រស់នៅ ឬ អាស្រ័យផល ដែលផ្ទុយនឹងឆន្ទៈរបស់ពួកគាត់។
- **វិវាទដីធ្លី៖** ការមិនឯកភាពរវាងគូរភាគីចាប់ពីពីរឡើង ទាក់ទិននឹងសិទ្ធិក្នុងការកាន់កាប់ ការគ្រប់គ្រង អាស្រ័យផល ឬ ការប្រើប្រាស់ដីជាក់លាក់លើផ្ទៃណាមួយនៃក្បាលដី។ វិវាទដីធ្លី អាចពាក់ព័ន្ធលើដីទាំងមូល ឬ ដីមួយចំណែក និងអាចទាក់ទិនទៅនឹងព្រំប្រទល់ក្បាលដីដែលជាប់គ្នា។
- **ដីប្រើប្រាស់ច្រើនយ៉ាង៖** សំដៅលើដីទំនាស់ ដែលត្រូវបានប្រើសម្រាប់គោលបំណងច្រើនយ៉ាង រួមមាន ដីដាំបន្លែនិងដំណាំ ដីស្រែនិងចំការ ព្រមទាំងដីលំនៅឋាន។ល។
- **អ្នកកាន់កាប់ដីដើម៖** សំដៅលើបុគ្គលម្នាក់ ឬបុគ្គលច្រើននាក់ ដែលបានប្រើឬបានកាន់កាប់ដី មុនពេលទំនាស់កើតឡើង។
- **ភាគីវិវាទ៖** សំដៅលើបុគ្គលដែលព្យាយាមទាមទារដីរបស់អ្នកកាន់កាប់ដីដើម។
- **ករណីស្ងៀមស្ងាត់៖** សំដៅលើករណីដែលត្រូវបានដាក់ជូនអាជ្ញាធរមាន

សមត្ថកិច្ច ប៉ុន្តែនៅមិនទាន់ដំណោះស្រាយ។

- **បណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន(LAHRiN)៖** គឺជាបណ្តាញអង្គការ មិនមែនរដ្ឋាភិបាល ដែលធ្វើការលើបញ្ហាសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាននៅកម្ពុជា ដែលសម្របសម្រួលដោយវេទិកានៃអង្គកាមិនមែនរដ្ឋាភិបាលស្តីពី កម្ពុជា (NGOF)។ បណ្តាញនេះ រួមមាន៖

  ១) គណៈកម្មាធិការដឹកនាំ មានសមាសភាពជានាយកនៃបណ្តាអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានជ្រើសរើស។

  ២) គណៈកម្មាធិការថ្នាក់ជាតិនៃបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន (LAHRiN) មានសមាសភាពជានាយកកម្មវិធី ឬនាយកគម្រោងនៃអង្គការមិនមែនរដ្ឋាភិបាលជាសមាជិកដែលមានទីស្នាក់ការនៅរាជធានីភ្នំពេញ និង

  ៣) សមាជិកថ្នាក់ខេត្តនៃបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន (LAHRiN) រួមមានបណ្តាអង្គការមិនមែនរដ្ឋាភិបាលដែលមាន ទីស្នាក់ការនៅតាមខេត្តនានា និងធ្វើការលើបញ្ហាសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន។

- **វិវាទដោះស្រាយចប់ពេញលេញទាំងស្រុង៖** សំដៅទៅដល់វិវាទទាំងឡាយណាដែលបានដោះស្រាយដល់គ្រប់គ្រួសាររងផលប៉ះពាល់ដោយវិវាទចប់សព្វគ្រប់។

១. សេចក្តីផ្តើម

វិវាទដីធ្លីនៅកម្ពុជា ត្រូវបានគេមើលឃើញជាទូទៅថាជាបញ្ហាមួយក្នុងចំណោមបញ្ហាប្រឈមដ៏ធំបំផុត ដែលប្រជាពលរដ្ឋកម្ពុជាកំពុងប្រឈមមុខ។ នៅក្នុងករណីធ្ងន់ធ្ងរ វិវាទដីធ្លីអាចឈានទៅដល់ការបាត់បង់ដីធ្លី និងការទទួលបានន្យវធនធានដែលមិនស្របទៅនឹងគោលដៅកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ កម្រិត និងការកើតមានវិវាទដីធ្លីនៅកម្ពុជា បង្កើតឱ្យមានកង្វល់ក្នុងចំណោមសហគមន៍ជាតិ និងអន្តរជាតិ។

តាមរយៈកំណត់ត្រាផ្នែកស្រាវជ្រាវនិងទិន្នន័យ របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បង្ហាញថា ករណីវិវាទដីធ្លីមួយចំនួន បានអូសបន្លាយជាច្រើនឆ្នាំ ហើយប្រការនេះ បានធ្វើឱ្យស្ថានភាពរស់នៅនិងជីវភាពរបស់ប្រជាជនរងផលប៉ះពាល់ធ្លាក់ចុះ។ កំណត់ត្រានេះ បង្ហាញថា មានកត្តាជាច្រើនដែលបង្កឱ្យមានវិវាទដីធ្លី រួមមាន គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ទីក្រុងនិងជនបទ សម្បទានដីសេដ្ឋកិច្ច សម្បទានផ្សេងៗទៀត ដែលប្រតិបត្តិដោយស្ថាប័នជាតិ ការតាំងទីលំនៅលើដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ និងក្រុមហ៊ុនអន្តរជាតិ និងការរំលោភយកដីពីសំណាក់បុគ្គលជាដើម។

ច្បាប់ តម្រូវឱ្យមានការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាននិងសង្គម(SEIA) សម្រាប់គម្រោងអភិវឌ្ឍន៍ទាំងឡាយ។ ប៉ុន្តែជាញឹកញាប់គម្រោងទាំងនោះមិនបានធ្វើការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាននិងសង្គមទេ ឬនៅពេលគម្រោងធ្វើការវាយតម្លៃ គឺធ្វើទាបជាងស្តង់ដាដែលបានកំណត់ ដោយផ្តល់ឱកាសតិចតួចសម្រាប់ការចូលរួមជាសាធារណៈ ដែលនាំឱ្យមិនមានការអនុវត្តច្បាប់ ដើម្បីការពារសិទ្ធិរបស់សហគមន៍មូលដ្ឋាន និងជំរុញឱ្យមានវិវាទដីធ្លីកាន់តែធ្ងន់ធ្ងរ មិនស្របទៅនឹងគោលដៅអភិវឌ្ឍន៍ជាតិ។

"**ការវិភាគស្ថិតិស្តីពីវិវាទដីធ្លីនៅកម្ពុជា**" របស់អេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានបង្កើតនិងចងក្រងទិន្នន័យតាំងពីឆ្នាំ២០០៧មកម្លេះ។ តាមរយៈស្ថិតិទាំងនេះ យើងឃើញថា វិវាទដីធ្លីកើនឡើងខ្ពស់បំផុតក្នុងឆ្នាំ២០០៨ ស្របពេលដែលតម្លៃដីនៅកម្ពុជាបានកើនឡើងយ៉ាងខ្លាំង។ នៅឆ្នាំបន្ទាប់ ចំនួនវិវាទដីធ្លី បានធ្លាក់ចុះបន្តិច ប៉ុន្តែក្នុងឆ្នាំ២០១០ ២០១១ និង២០១២ ចំនួនវិវាទដីធ្លី បានចាប់ផ្តើមកើនឡើងម្តងទៀត។ ករណីវិវាទថ្មីៗក្នុងឆ្នាំ២០១៣ ឆ្នាំ២០១៤ និងឆ្នាំ២០១៥បានធ្លាក់ចុះម្តងទៀត បើធៀបទៅនឹងកំណត់ត្រានៅមុនឆ្នាំ២០១២ ប៉ុន្តែនៅក្នុងឆ្នាំ២០១៦ ករណីវិវាទថ្មីៗមានការកើនឡើងខ្ពស់ជាងបណ្តាឆ្នាំមុនៗ ទាំងអស់។

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តមួយចំនួន ទាក់ទិនទៅនឹងដីធ្លីនិងធនធានធម្មជាតិ ដែលសំដៅដល់ការអនុវត្តនីតិវិធីទាំងឡាយ ពាក់ព័ន្ធនឹងរដ្ឋបាលនិងការគ្រប់គ្រងដីធ្លី រួមទាំង ការទប់ស្កាត់វិវាទដីធ្លី និងដំណោះស្រាយវិវាទដីធ្លី។[1] បទបញ្ជា ០១ បានរៀបចំជាយន្តការដើម្បីផ្អាកជាបណ្តោះអាសន្នលើការផ្តល់សម្បទានដីសេដ្ឋកិច្ច អនុវត្តគោលនយោបាយស្បែកខ្លា ចំពោះប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយ សារក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច/សម្បទានដីនានា ការលុបចោលសម្បទានដីសេដ្ឋកិច្ច/សម្បទានដី ដែលមិនបានអនុវត្តតាមផែនការវិនិយោគរបស់ក្រុមហ៊ុន ដូចដែលបានកំណត់ក្នុងកិច្ចសន្យាវិនិយោគ។ យន្តការនេះរំពឹងថានឹងអាចដោះ ស្រាយបញ្ហា

---

[1] ឧទាហរណ៍: ច្បាប់ភូមិបាលដែលត្រូវបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០១, សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីគោលនយោបាយដីធ្លី (ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៧), ច្បាប់ស្តីពីអស្សាមិករណ៍ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១០, សារាចរលេខ ០៣ ស្តីពីដំណោះស្រាយសំណង់បណ្តោះអាសន្ន ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១០, គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ឆ្នាំ ២០០៩, អនុក្រឹត្យលេខ ៨៣ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីសម្រាប់ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច (L&R/L&P/២០០៩/Khm) (Ogs, ឆ្នាំ ២០០៩, លេខ ៨៣ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៩) និង ប្រកាសអន្តរក្រសួងស្តីពីវិធានការបណ្តោះអាសន្នការពារដីរបស់ជនជាតិដើមភាគតិច ដែលត្រូវបានស្នើសុំប័ណ្ណកម្មសិទ្ធិសម្បហាភាព ខណៈពេលរង់ចាំការផ្តល់ប័ណ្ណកម្មសិទ្ធិយោងតាមនីតិវិធីដែលត្រូវបញ្ចប់នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១។

វិវាទដីធ្លីបានកាន់តែប្រសើរ។ ប្រកាសអន្តរក្រសួងស្តីពីការពង្រឹងការគ្រប់គ្រងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដែលចុះសហត្ថលេខាដោយ ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម និងឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន កាលពីថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៤ ត្រូវបានចាត់ទុកថាជាយន្តការដើម្បីកាត់បន្ថយវិវាទដីធ្លីរបស់រដ្ឋាភិបាលក្នុងអណាត្តិទីប្រាំ។ ការបង្កើតក្រុមការងារដោះស្រាយ ទំនាស់ដីធ្លីចំនួន ២៧ ក្រុមក្នុង ខែមិថុនា ឆ្នាំ២០១៦ ដើម្បីទទួលខុសត្រូវការ ដោះស្រាយតាមខេត្តគោលដៅតាមខេត្តនិមួយៗ។

ទោះជាយ៉ាងណាក៏ដោយ គេនៅមិនទាន់ដឹងច្បាស់ទេថាតើគោលនយោបាយ និងក្របខ័ណ្ឌថ្មីៗទាំងនោះ អាចអនុវត្តជោគជ័យកំរិតណា ពាក់ព័ន្ធទៅនឹងដំណោះស្រាយវិវាទដីធ្លី។ វិវាទដីធ្លីនៅកម្ពុជា នៅតែត្រូវបានរាយការណ៍ជាច្រើន ទាំងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាតិនិងអន្តរជាតិ។ ទិន្នន័យដែលបង្ហាញនៅក្នុងរបាយការណ៍នេះ អាចខុសពីទិន្នន័យដែលបានផ្សព្វផ្សាយដោយអង្គការដទៃៗទៀត ដោយសារការប្រើប្រាស់វិធីសាស្ត្រខុសៗគ្នានៃការប្រមូលព័ត៌មាន។ របាយការណ៍នេះ សំដៅតាមដានមើលនូវនិន្នាការនៅក្នុងការកើតឡើង និងមូលហេតុនៃវិវាទដីធ្លីដែលប្រមូលដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងផ្តល់ភស្តុតាងជាឯកសារសំរាប់ភាគីពាក់ព័ន្ធនានា ដែលចង់ស្វែងយល់ពីបញ្ហាដ៏សំខាន់នេះ។

២. គោលបំណងនៃរបាយការណ៍

របាយការណ៍នេះ មានគោលបំណងផ្តល់នូវភស្តុតាងជាឯកសារនៃវិវាទដីធ្លីដែលកើតមានតាមបណ្តាឆ្នាំកន្លងមក រហូតដល់ឆ្នាំ២០១៦។ ទិន្នន័យទាំងនេះ បានប្រមូលពីអត្ថបទនានា ស្តីពីវិវាទដីធ្លីតាមរយៈសារព័ត៌មានបោះពុម្ពផ្សាយក្នុងស្រុក កិច្ចប្រជុំជាមួយសមាជិកបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន(LAHRiN) និងតាមរយៈការប្រមូលទិន្នន័យនៅមូលដ្ឋាន។ របាយការណ៍នេះ មានបំណងលើកកម្ពស់ការ

យល់ដឹងអំពីស្ថានភាពបច្ចុប្បន្នទាក់ទិននឹងវិវាទដីធ្លី និងបំពេញមុខងារជាធនធានមួយសម្រាប់ភាគីពាក់ព័ន្ធផ្សេងៗទៀត ដែលធ្វើការលើបញ្ហាដីធ្លី រួមមាន មន្ត្រីរាជរដ្ឋាភិបាល ម្ចាស់ជំនួយ សមាជិកបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន(LAHRiN) អង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិ និងអ្នកសិក្សាស្រាវជ្រាវនានា។ របាយការណ៍នេះ ក៏អាចនឹងប្រើប្រាស់ជាឯកសារ ក្នុងការតស៊ូមតិដើម្បីលើកស្ទួយសុវត្ថិភាពកាន់កាប់ដីសម្រាប់ប្រជាជនក្រីក្រ និងងាយរងគ្រោះនៅកម្ពុជាផងដែរ។

លើសពីនេះទៅទៀត ខ្លឹមសារនៃរបាយការណ៍នេះ ក៏នឹងមានប្រយោជន៍ចំពោះភាគីពាក់ព័ន្ធ និងរាជរដ្ឋាភិបាលដែលកំពុងធ្វើការដើម្បីស្វែងរកដំណោះស្រាយ ចំពោះស្ថានភាពដីធ្លីបច្ចុប្បន្ននៃប្រទេសកម្ពុជា។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា អាចដឹងថាលទ្ធផលនៃរបាយការណ៍នេះ អាចនឹងត្រូវបដិសេដក្តី ក៏យើងនៅតែសង្ឃឹមថា លទ្ធផលនៃការវិភាគវិវាទដីធ្លីនេះ នឹងចូលរួមចំណែកដល់ការអនុវត្តគោលនយោបាយនិងសកម្មភាពនានា ដែលនឹងនាំទៅដល់ដំណោះស្រាយចំពោះវិវាទដីធ្លីនៅកម្ពុជា។

៣. វិធីសាស្ត្រ

៣.១ លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ករណីវិវាទដីធ្លី

របាយការណ៍នេះ វិភាគរាល់វិវាទដីធ្លីដែលបានរាយការណ៍នៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុក និងព័ត៌មានដែលប្រមូលបានពីសមាជិកបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន។ ដោយឡែកវិវាទដីធ្លីដែលបានកើតឡើង ប៉ុន្តែមិនមានចុះផ្សាយដោយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុក ហើយសមាជិកបណ្តាញញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋានមិនបានដឹង គឺមិនមាននៅក្នុងការវិភាគនេះទេ។ វិវាទដីធ្លីដែលបានផ្សព្វផ្សាយនៅប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុក អាចកើតឡើងលើដីមាន

ប័ណ្ណកម្មសិទ្ធិ ឬដីគ្មានប័ណ្ណកម្មសិទ្ធិ។

ស្ថិតិដែលបង្ហាញនៅក្នុងរបាយការណ៍នេះ អាចខុសពីប្រភពផ្សេងៗទៀត ដោយសារភាពខុសគ្នានៅក្នុងវិធីសាស្ត្រ និងលក្ខណៈវិនិច្ឆ័យនៃការប្រមូល និងការផ្ទៀងផ្ទាត់ទិន្នន័យ។ ផ្នែកស្រាវជ្រាវនិងទិន្នន័យរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីកម្ពុជា ប្រើលក្ខណៈវិនិច្ឆ័យខាងក្រោម ដើម្បីកំណត់ករណីវិវាទដីធ្លី៖

- ករណីវិវាទដីធ្លីដែលពាក់ព័ន្ធចាប់ពី ៥គ្រួសារឡើង
- ករណីវិវាទដីធ្លីដែលនៅមិនទាន់ត្រូវបានដោះស្រាយ ឬ ដែលដោះស្រាយបានមួយផ្នែក និង
- ករណីវិវាទដីធ្លីដែលបានដោះស្រាយមុនឆ្នាំ២០១៦ ត្រូវដកចេញពីការវិភាគនេះ។ ប៉ុន្តែករណីដែលដោះស្រាយចប់ក្នុងឆ្នាំ២០១៦ ត្រូវដាក់បញ្ចូលក្នុងការវិភាគនេះ។

៣.២ ការប្រមូលទិន្នន័យ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីពីវិវាទដីធ្លី

ប្រព័ន្ធប្រមូលព័ត៌មាន និងការធ្វើបច្ចុប្បន្នភាពទិន្នន័យរបស់ផ្នែកស្រាវជ្រាវនិងទិន្នន័យរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីកម្ពុជា មានដូចខាងក្រោម៖

ជំហានទី១៖

- ការប្រមូលព័ត៌មានប្រចាំថ្ងៃស្តីពីករណីវិវាទដីធ្លី ធ្វើតាមរយៈការតាមដានមើលប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុក (រួមមានកាសែតភ្នំពេញប៉ុស្ត វិទ្យុអាស៊ីសេរី វិទ្យុបារាំងអន្តរជាតិ កាសែតខេមបូឌាដេលី កាសែតកោះសន្តិភាព កាសែតរស្មីកម្ពុជា ហ្វេសបុកផេក វាយោ វីអូឌី។ល។

ជំហានទី២៖

- ដោយផ្អែកលើព័ត៌មានប្រមូលបាន ករណីវិវាទដីធ្លីនិមួយៗ ត្រូវឆ្លងកាត់កិច្ចដំណើរការផ្ទៀងផ្ទាត់មួយ ដើម្បីជៀសវាងការដាក់បញ្ចូលត្រួតគ្នាទៅក្នុងប្រព័ន្ធទិន្នន័យ ជាមួយសមាជិកបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន (LAHRiN) ថ្នាក់ខេត្ត តាមរយៈកិច្ចប្រជុំបណ្តាញរាល់បីខែម្តង។
- កិច្ចប្រជុំរាល់ប្រចាំត្រីមាស ក៏ជាឱកាសមួយដែលមិនត្រឹមតែដើម្បីធ្វើការផ្ទៀងផ្ទាត់ករណីវិវាទដីធ្លីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីប្រមូលព័ត៌មានស្តីពីវិវាទដីធ្លីទាំងឡាយ ដែលមិនបានរាយការណ៍នៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន កំពុងកើតឡើងនៅក្នុងតំបន់គោលដៅរបស់សមាជិកបណ្តាញ។

ជំហានទី៣៖

- សមាជិកបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន(LAHRiN) ថ្នាក់ខេត្ត ធ្វើការផ្ទៀងផ្ទាត់វិវាទដីធ្លីនៅមូលដ្ឋាន។ ដើម្បីប្រមូលទិន្នន័យពាក់ព័ន្ធ សមាជិកត្រូវបានតម្រូវប្រើទំរង់មួយ ដែលត្រូវបានរៀបចំដោយផ្អែកស្រាវជ្រាវ តស៊ូមតិ និងទំនាក់ទំនង។
- ផ្អែកស្រាវជ្រាវនិងទិន្នន័យ ធ្វើយុទ្ធនាការប្រចាំឆ្នាំមួយ ដើម្បីធ្វើបច្ចុប្បន្នភាព និងផ្ទៀងផ្ទាត់ទិន្នន័យវិវាទដីធ្លីទូទាំងប្រទេស។ យុទ្ធនាការនេះ ធ្វើឡើងដោយមានកិច្ចសហការជាមួយសមាជិកបណ្តាញសិទ្ធិដីធ្លីនិងសិទ្ធិលំនៅឋាន(LAHRiN) ថ្នាក់ខេត្តនិមួយៗ ដែលធ្វើនៅក្នុងខែវិច្ឆិការៀងរាល់ឆ្នាំ។

ជំហានទី៤៖

- ការប្រជុំពិគ្រោះលើរបាយការណ៍ស្ថិតិវិវាទដីធ្លី ដោយមានការចូលរួមពីសមាជិកបណ្តាញសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន (LAHRiN) សមាជិក

បណ្តាញជនជាតិដើមភាគតិច និងព្រៃឈើ (IPFN) អង្គការសង្គមស៊ីវិល ម្ចាស់ជំនួយ និងអង្គការដៃគូរមុនបោះពុម្ពផ្សព្វផ្សាយនូវរបាយការណ៍។

តារាងសង្ខេបអំពីវិធីសាស្ត្រ



៣.៣ ឧបករណ៍ប្រើប្រាស់ដៅក្នុងការវិភាគស្ថិតិ

ទិន្នន័យវិវាទដីធ្លីទាំងអស់ដែលប្រមូលបាន ត្រូវបានកត់ត្រាទុកក្នុងមូលដ្ឋានទិន្នន័យរបស់ផ្នែកស្រាវជ្រាវនិងទិន្នន័យ។ កម្មវិធីកុំព្យូទ័រមួយចំនួន រួមមាន Microsoft Excel, Statistical Package for the Social Science (SPSS software) និងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (Geographic Information System (GIS) ត្រូវបានប្រើប្រាស់សម្រាប់វិភាគករណីទាំងនោះ ដោយផ្តល់នូវស្ថិតិរួមមួយអំពីវិវាទដីធ្លី និងទីកន្លែងភូមិសាស្ត្រនៃវិវាទដីធ្លី។

៤. យន្តការដោះស្រាយវិវាទ

នៅក្នុងបរិបទនៃវិវាទដីធ្លី ការសំខាន់គឺត្រូវបែងចែករវាងវិវាទលើដី "គ្មានប័ណ្ណកម្មសិទ្ធិ" ពោលគឺដីដែលពុំមានការចេញប័ណ្ណកម្មសិទ្ធិផ្លូវការ និង វិវាទលើដី "មានប័ណ្ណកម្មសិទ្ធិ"។ យន្តការនៃការដោះស្រាយវិវាទដីធ្លី មានផ្សេងគ្នា និងអាស្រ័យទៅលើប្រភេទនៃវិវាទនិមួយៗ។ នៅកម្ពុជា មានយន្តការចំនួនប្រាំមួយ ក្នុងការដោះស្រាយវិវាទដីធ្លីផ្លូវការ។ យន្តការដោះស្រាយវិវាទទាំងនេះ រួមមាន៖

- ក្រុមប្រឹក្សាឃុំ/សង្កាត់
- គណៈកម្មការសុរិយោដី
- គណៈកម្មការរដ្ឋបាល
- អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ក្រុមការងារដោះស្រាយទំនាស់ដីធ្លី
- តុលាការ

ក្រុមប្រឹក្សាឃុំ/សង្កាត់៖ មានភារៈកិច្ច "ផ្សះផ្សារនូវគំនិតដែលផ្ទុយ" រវាងប្រជាពលរដ្ឋក្នុងឃុំ ប៉ុន្តែមិនមានអំណាចធ្វើសេចក្តីសម្រេចឡើយ។ បើទោះបីជាមិនមាននីតិវិធីដោះស្រាយវិវាទដីធ្លីផ្លូវការសម្រាប់ក្រុមប្រឹក្សាឃុំ/សង្កាត់ក៏ដោយ គេនៅតែឃើញមានករណីបណ្តឹងភាគច្រើន បានដាក់ចូលមកក្រុមប្រឹក្សាឃុំ/សង្កាត់ មុនពេលករណីទាំងនោះដាក់ទៅថ្នាក់លើ។

គណៈកម្មការសុរិយោដី៖ មានយុត្តាធិការចំពោះវិវាទលើដីគ្មានប័ណ្ណកម្មសិទ្ធិ (*អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ មាត្រា៦*)។ គណៈកម្មការសុរិយោដី មាននៅកម្រិតស្រុក/ខណ្ឌ ដែលហៅថា "គណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌ(DKCC)" បន្ទាប់មកនៅកម្រិតខេត្ត/ក្រុង ហៅថា "គណៈកម្មការសុរិយោដីថ្នាក់ខេត្ត/ក្រុង(PMCC)" និងនៅថ្នាក់ជាតិ

ហៅថា "គណៈកម្មការសុរិយោដីថ្នាក់ជាតិ(NCC)"។ ក្នុងករណីវិវាទដែលមិនអាចឈានដល់ដំណោះស្រាយប្រកបដោយសមធម៌ គណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌ ត្រូវបញ្ជូនសំណុំរឿងវិវាទ ជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត/ក្រុង យោងតាមមូលហេតុដូចខាងក្រោម[2]៖

(១) បុគ្គលម្នាក់ទាមទារកាន់កាប់ក្បាលដីមួយចំនួន ដែលដីទាំងនោះត្រូវបានទាមទារដោយអ្នកកាន់កាប់ដីដទៃទៀតដែរ។

(២) ភាគីមួយនៃភាគីទំនាស គឺជាអាជ្ញាធរថ្នាក់ខ្ពស់។

(៣) មានទំនាស់ផលប្រយោជន៍ជាមួយប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌ។

(៤) វិវាទពាក់ព័ន្ធដីសាធារណៈរបស់រដ្ឋ។[3]

ជាទូទៅ ករណីវិវាទនិមួយៗនឹងត្រូវឆ្លងកាត់នីតិវិធីជាច្រើន ដូចជា ការដាក់ពាក្យបណ្តឹង ការស៊ើបអង្កេត កិច្ចប្រជុំរដ្ឋបាល ការផ្សះផ្សារ និងការចុះបញ្ជីដី។ បន្ទាប់ពីមានកិច្ចប្រឹងប្រែងផ្សះផ្សារវិវាទដីធ្លី បើដងរូចមក [4] គណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌ ដែលជាគណៈកម្មការថ្នាក់ក្រោម មិនមានអំណាចធ្វើសេចក្តីសម្រេចលើវិវាទណាមួយឡើយ គឺអាស្រ័យទៅសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត/ក្រុង និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

សម្រាប់ឆ្នាំ២០១៦នេះ យន្តការគណៈកម្មការសុរិយោដី បានដោះស្រាយ

---

[2] *យន្តការដោះស្រាយវិវាទកម្ពុជា, កម្មវិធីសិទ្ធិដីធ្លីទី ២ នៃអង្គការ GIZ, ខែ សីហា ឆ្នាំ ២០១៤, បទបង្ហាញក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសផ្នែកដីធ្លីជាមួយដៃគូអភិវឌ្ឍន៍, ខែ សីហា ឆ្នាំ ២០១៤*

[4] *(មាត្រា ២៩, លេខ ១១២ ដនស/ប្រក, ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២, ប្រកាសស្តីពីគោលការណ៍ណែនាំ និង នីតិវិធីនៃគណៈកម្មការសុរិយោដី, សូមមើលយន្តការដោះស្រាយវិវាទកម្ពុជា, កម្មវិធីសិទ្ធិដីធ្លីទី ២ នៃអង្គការ GIZ, ខែ សីហា ឆ្នាំ ២០១៤, បទបង្ហាញក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសផ្នែកដីធ្លីជាមួយដៃគូអភិវឌ្ឍន៍, ខែ សីហា ឆ្នាំ ២០១៤)*

បញ្ចប់វិវាទ ចំនួន២៣៥ករណី ដែលក្នុងមានប្រជាពលរដ្ឋរងផលប៉ះពាល់ចំនួន ១,២៧១.០០ គ្រួសារ លើផ្ទៃដីទំហំ ១៤៥.៤០ ហិកតា[5]។

គណៈកម្មការរដ្ឋបាល(AC) គណៈកម្មការនេះមិនមែនជាយន្តការដោះស្រាយវិវាទ អចិន្ត្រៃយ៍ទេ។ គណៈកម្មការរដ្ឋបាល មានវត្តមានជាលក្ខណៈបណ្តោះអាសន្ន ក្នុងអំឡុងពេលដំណើរការនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ។ គណៈកម្មការរដ្ឋបាល មានភារកិច្ចផ្សះផ្សារវិវាទ លើក្បាលដីនៅមិនទាន់មានប័ណ្ណកម្មសិទ្ធិ ទោះបីជាការទាមទារដោយបុគ្គល ក្រុមហ៊ុន ឬទាមទារដោយរដ្ឋ។ ករណីវិវាទដែលមិនអាចផ្សះផ្សារបាន ត្រូវបញ្ជូនទៅកាន់គណៈកម្មការសុរិយោដីថ្នាក់ជាតិ[6]។

អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(NALDR) មានយុត្តាធិការលើករណីទាំងឡាយណាដែល "ហួសពីយុត្តាធិការ" របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធវិវាទដីធ្លី[7]។ អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី ត្រូវបានដឹកនាំដោយឧបនាយករដ្ឋមន្ត្រីមួយរូប និងមានក្រសួងអាជ្ញាធរចំនួន២៦ ជាសមាជិក។ សមាជិក១០រូប ផ្សេងទៀតបំពេញមុខងារជាអគ្គលេខាធិការដ្ឋាន ដែលដឹកនាំដោយគណៈរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ។

ក្រុមការងារដោះស្រាយទំនាស់ដីធ្លី ជាក្រុមការងារមួយត្រូវបានបង្កើតឡើងនៅក្នុងខែឧសភា ឆ្នាំ២០១៦ ក្នុងគោលបំណងដោះស្រាយទំនាស់ដីធ្លីជាបន្ទាន់តាមបណ្តាខេត្ត រាជធានីទូទាំងប្រទេស ការដោះស្រាយរាល់ករណីវិវាទគឺឈរលើគោលការណ៍សម្របសម្រួលរវាងភាគីវិវាទ ករណីទំនាស់និមួយៗដែលទទួលបានពីដើមបណ្តឹងត្រូវបានចាត់ចែងក្រុមការងារដោះស្រាយ ដោយមានកំណត់សមាសភាពច្បាស់លាស់ក្នុងការទទួលខុសត្រូវ ព្រមទាំងមានលេខសំរាប់ទំនាក់ទំនងតាមក្រុម

---

[5] http://bit.ly/2qpKX7o

[6] *ដូចយោងខាងលើ*

[7] *មាត្រា ៣, រាជក្រឹត្យ លេខ រស/រតក/០២០៦/៦៩៧*

និមួយៗផងដែរ។ គិតត្រឹម ខែសីហា ឆ្នាំ២០១៦ ក្រសួងបានបង្កើតក្រុមការងារចុះដោះស្រាយទំនាស់ដីធ្លីចំនួន ២៧ក្រុម ដើម្បីធ្វើការដោះស្រាយចំពោះករណីទំនាស់ដីធ្លីដែលក្រសួងបានទទួល ចំនួន៨២ករណី។ នៅក្នុងភាពទទួលខុសត្រូវក្នុងការដោះស្រាយចំពោះករណីទំនាស់ដីធ្លីដែលក្រសួងបានទទួល ករណីទំនាស់ទាំងនោះត្រូវបានបានចែកទៅតាមក្រុមនិមួយៗ ដោយមានសមាសភាពចូលរួមច្បាស់លាស់ក្នុងមួយក្រុមមានប្រធាន និងសមាជិកចំនួន ៤នាក់ ហើយក្នុងមួយក្រុមទទួលខុសត្រូវយ៉ាងតិចចំនួន ៣ករណី និងច្រើនបំផុតចំនួន ៥ករណី។ ជាក់ស្តែងសម្រាប់ឆ្នាំ ២០១៦ ក្រុមការងារដោះស្រាយវិវាទដីធ្លីនេះ ទទួលបានពាក្យបណ្តឹងចំនួន ៧៥៧ បណ្តឹង ដោយក្នុងនោះ ករណីវិវាទចំនួន ៥៤ករណី បានដោះស្រាយបញ្ចប់ និងវិវាទចំនួន ៧១ករណី បានធ្វើការឆ្លើយតបទៅម្ចាស់បណ្តឹង ឬបង្ហៀទៅសមត្ថកិច្ចពាក់ព័ន្ធ[8] ។

តុលាការ មានអាណត្តិដោះស្រាយវិវាទលើដីមានប័ណ្ណកម្មសិទ្ធិ។ អំណាចរបស់ស្ថាប័នតុលាការ មានបីកម្រិត ដូចជា សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ប្រជាពលរដ្ឋក្រីក្រពុំមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធតុលាការ ក្នុងការដោះស្រាយវិវាទនោះទេ ដោយសារថ្លៃសេវាខ្ពស់ពេក។

[8] http://bit.ly/2qpKX7o

តារាងខាងក្រោមបង្ហាញហានុក្រមនៃយន្តការដោះស្រាយវិវាទ៖



ប្រភព: យន្តការដោះស្រាយវិវាទកម្ពុជា, កម្មវិធីសិទ្ធិដីធ្លីទី ២ នៃអង្គការ GIZ, ខែ សីហា ឆ្នាំ ២០១៤, បទបង្ហាញក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសផ្នែកដីធ្លីជាមួយដៃគូអភិវឌ្ឍន៍, ខែ សីហា ឆ្នាំ ២០១៤។

៥. លទ្ធផលនៃការវិភាគទិន្នន័យ

ទិន្នន័យនិងក្រាហ្វិកដែលបង្ហាញជូនក្នុងរបាយការណ៍នេះ គឺពឹងផ្អែកទៅលើមូលដ្ឋានទិន្នន័យរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ដែលបានរៀបចំនិងចងក្រងទុកតាំងពីឆ្នាំ២០០៧មក។

៥.១ ចំនួនដីធ្លីគិតតាមឆ្នាំ

សរុបករណីវិវាទដីធ្លីថ្មីដែលកើតឡើងក្នុងឆ្នាំ២០១៦ មានចំនួន ៥៦[9] ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យរបស់អ្នកស្រាវជ្រាវដូចបានកំណត់ខាងលើ។ ករណីវិវាទថ្មីក្នុងឆ្នាំ២០១៦នេះ មានចំនួនច្រើនជាងបណ្តាឆ្នាំនានាដែលយើងបានធ្វើការកត់ត្រា

[9] *សូមមើលឧបសម្ព័ន្ធទី ១។*

តាំងពីឆ្នាំ ២០០៧មកនោះ។ ធៀបទៅនឹងវិវាទកើតថ្មីក្នុងឆ្នាំ២០១៥ មានចំនួន២៣ ករណី ឃើញថាវិវាទក្នុងឆ្នាំ២០១៦នេះ មានការកើនឡើងទ្វេដង ប៉ុន្តែបើយើងធ្វើការប្រៀបធៀបករណីវិវាទកើតថ្មីក្នុងឆ្នាំ២០១២ ជាឆ្នាំបោះឆ្នោតជ្រើសរើសឃុំសង្កាត់ ចំនួនវិវាទដីធ្លីក៏មានការកើនឡើងខ្ពស់ផងដែរ ដោយមានចំនួន៤៦ករណី ចំនួននេះធៀបនឹងឆ្នាំ២០១៦ មានចំនួន៥៦ករណី គឺប្រហាក់ប្រហែលគ្នា នេះអាចមកពីមានភាពពាក់ព័ន្ធទៅនឹងស្ថានភាពនយោបាយដូចគ្នា បានជះឥទ្ធិពលក្នុងការជម្រុញឲ្យប្រជាពលរដ្ឋធ្វើការប្តឹងតវ៉ាច្រើនលើបញ្ហាវិវាទដីធ្លី។

រូបទី ១: ករណីវិវាទដីធ្លីដែលកើតថ្មីៗតាមណ្តាឆ្នាំនិមួយៗ



វិវាទទាំងអស់នោះកើតមាននៅក្នុងខេត្តកំពង់ធំ ៦ករណី ខេត្តរតនគិរី និងមណ្ឌលគិរី ៥ករណីដូចគ្នា ខេត្តបាត់ដំបង ខេត្តកណ្តាល រាជធានីភ្នំពេញ និងខេត្តព្រះវិហារ ៤ករណីដូចគ្នា ខេត្តកំពង់ឆ្នាំង ខេត្តប៉ៃលិន និងខេត្តពោធិ៍សាត់ ៣ករណីដូចគ្នា ខេត្តបន្ទាយមានជ័យ ខេត្តក្រចេះ ខេត្តសៀមរាប និងខេត្តត្បូងឃ្មុំ ២ករណីដូចៗគ្នា ខេត្តកំពងចាម ខេត្តកោះកុង ខេត្តឧត្តរមានជ័យ ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង ខេត្តស្វាយរៀង និងខេត្តតាកែវ ១ករណីដូចគ្នា។ វិវាទទាំងអស់នោះគឺបង្ករឡើងដោយសារ ការរំលោភយកដីព្រៃសហគមន៍ធ្វើជាកម្មសិទ្ធិ ការវិនិយោគ

សម្បទានដីសេដ្ឋកិច្ច[10] ការកាប់ទន្ទ្រានដីព្រៃធ្វើជាកម្មសិទ្ធិឯកជន មាន៥ករណីដូចៗគ្នា។ ការកាប់ទន្ទ្រានិងការលក់ដូរដីព្រៃលិចទឹក មាន៤ករណី ការរំលោភយកដីកេរ្តិ៍សម្រាប់បញ្ចុះសព/ការកាប់ទន្ទ្រានរំលោភដីព្រៃតំនមនិងដីព្រៃកប់ខ្មោចរបស់ជនជាតិដើមភាគតិច មាន៣ករណី ការលក់ដូរដីរួមរបស់ភូមិ/ឃុំ/ស្រុក ការលក់ដីបឹងសារធារណៈ តម្រូវការដីសម្រាប់ធ្វើជាបន្ទាយទាហាន ការអាងលើតួនាទីជាមន្ត្រីយោធារំលោភយកដីប្រជាពលរដ្ឋ មាន២ករណីដូចៗគ្នា។ ការទិញលក់ដីក្នុងតំបន់បន្ទាយទាហាន ការកាប់ទន្ទ្រានដីព្រៃបំរុងទុកសម្រាប់ចាក់សម្រាមធ្វើជាកម្មសិទ្ធ ការអភិវឌ្ឍន៍ទីក្រុងរណប គម្រោងអភិវឌ្ឍន៍សាកលវិទ្យាល័យ ការជីកយកដីភ្នំធ្វើផ្លូវថ្នល់និងលក់ដោយអាជ្ញាធរមូលដ្ឋានឃុំនិងខេត្ត ការជីកកកាយដីភ្នំធ្វើជាកម្មសិទ្ធិ ការអភិវឌ្ឍន៍ផ្លូវល្បឿនលឿន ការកាប់ឆ្ការដីចំការម្រិចដែលមានប័ណ្ណកម្មសិទ្ធិតាំងពីឆ្នាំ ២០០៧ដោយសំអាងថាជាដីដូនតារបស់ជនជាតិដើមភាគតិច ការជីកដីបឹងសម្រាប់យកអាជ័ដីលក់ដោយអាជ្ញាធរមូលដ្ឋាន ការលក់ដីអូររួមរបស់ឃុំ ការជីកទំនប់ព័ទ្ធយកឡូត៍នេសាទរបស់រដ្ឋមកធ្វើជាកម្មសិទ្ធ ការធ្វើផ្លូវសម្រាប់ចូលទៅកាន់ទីតាំងក្រុមហ៊ុនវៀតណាម ការរំលោភកិច្ចសន្យាជួលនិងការទន្ទ្រានដីភ្នំធ្វើជាកម្មសិទ្ធ ការដាក់បញ្ចូលតំបន់ភ្នំគូលែនជាតំបន់បេតិកភ័ណ្ឌ ការផ្តល់ដីសម្បទានសង្គមកិច្ច ការជីកប្រឡាយរំលោភផ្លូវសាធារណៈ ការអភិវឌ្ឍន៍/ការសាង់សង់ប្រឡាយទឹក ជម្លោះលើប័ណ្ណសំគាល់សិទ្ធិកាន់កាប់ឆ្នាំ ១៩៩៣ (ប្លង់ស្លាបមាន់) ដោយសារអ្នកកាន់កាប់ជាក់ស្តែងគ្មានប័ណ្ណ ការរៀបចំដីពុះឡូត៍សម្រាប់លក់ ការធ្វើចលនាប្រជាពលរដ្ឋឲ្យផ្តិតមេដៃលើលិខិតលក់ទិញដោយមិនបានដឹងថាលក់ដីតំបន់ណាមួយជាក់លាក់ ការដាក់ដីព្រៃរបោះដែលប្រជាពលរដ្ឋធ្វើកមសិកម្មទុកជាព្រៃការពារសម្រាប់អភិរក្សសត្វព្រៃនិងព្រៃឈើទំហំ១៩៩ហិកតា ការស្តារប្រឡាយទឹកស្អុយដើម្បីរំដោះទឹកចេញពីរាជធានីភ្នំពេញ(គម្រោងអភិវឌ្ឍន៍ ប្រឡាយ) មាន១ករណីដូចៗគ្នា និងផ្សេ

[10] *សូមបញ្ជាក់ថាវិវាទនេះមិនមែនដោយសារជាការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មីនោះទេ។ វាជាវិវាទដែលកើតឡើងនៅពេលដែលក្រុមហ៊ុនធ្វើសកម្មភាពលើផ្ទៃដីដែលទទួលបានវិនិយោគកន្លងមក។*

ងៗទៀត មាន៤ករណី។

សម្រាប់ករណីដែលកើតថ្មីក្នុងឆ្នាំ២០១៦នេះ មានចំនួន ១០ករណីបានធ្វើការដោះស្រាយចប់ពេញលេញទាំងស្រុងក្នុងឆ្នាំដដែលនេះដែរ វិវាទទាំងនោះមាននៅក្នុងខេត្តកំពង់ឆ្នាំង និងខេត្តប៉ៃលិនដោះស្រាយចប់ចំនួន ២ករណីដូចគ្នា ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តក្រចេះ ខេត្តពោធិ៍សាត់ ខេត្តសៀមរាប និងខេត្តស្វាយរៀង ដោះស្រាយចប់ចំនួន ១ករណីដូចៗគ្នា។ សរុបមកមានករណីវិវាទដីធ្លីដែលកើតថ្មីក្នុងឆ្នាំ២០១៦ នៅសល់ ចំនួន៤៥ករណី មិនទាន់បានដោះស្រាយចប់។

៥.២ ទីតាំងនៃវិវាទ

នៅក្នុងករណីវិវាទដីធ្លីចំនួន ៣១៩ករណី [11] ដែលពុំទាន់និងកំពុងរងចាំការដំណោះស្រាយ មានករណីវិវាទមួយចំនួនដោះស្រាយបានលទ្ធផលមួយផ្នែក ប៉ុន្តែវិវាទមិនទាន់បានបញ្ចប់។ ករណីមួយចំនួនទៀត ទើបតែចាប់នៅក្នុងដំណើការនៃការដំណោះស្រាយវិវាទជាមួយនឹងនីតិវិធីមិនច្បាស់លាស់ ហើយករណីមួយចំនួនទៀតនៅមានសភាព"ស្ងៀមស្ងាត់" ដែលមានន័យថា បណ្តឹងត្រូវបានដាក់ជូនស្ថាប័នមានសមត្ថកិច្ចនិងអាជ្ញាធរួចហើយ ប៉ុន្តែពុំមានចំណាត់ការដោះស្រាយនៅឡើយ។

វិវាទដីធ្លីទាំងនោះ កើតមាននៅទូទាំង ២៤ខេត្ត និងរាជធានីភ្នំពេញ។ វិវាទទាំងនោះកើតមាននៅក្នុងខេត្តរតនគិរី មាន៣១ករណី រាជធានីភ្នំពេញ មាន២៩ករណី ខេត្តបន្ទាយមានជ័យ មាន២៣ករណី ខេត្តសៀមរាប មាន២១ករណី ខេត្តព្រះសីហនុ និងខេត្តមណ្ឌលគិរី មាន១៩ករណី ខេត្តបាត់ដំបង និងខេត្តកំពង់ស្ពឺ មាន១៨ករណី ខេត្តពោធិ៍សាត មាន១៦ករណី ខេត្តកោះកុង មាន១៥ករណី ខេត្តព្រះវិហារ មាន១៤ករណី ខេត្តឧត្តរមានជ័យ និងខេត្តស្វាយរៀង មាន១២ករណី ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង មាន១០ករណី ខេត្តកំពង់ឆ្នាំង និងខេត្តត្បូងឃ្មុំ មាន៩ករណី

11 ករណីនេះរាប់បញ្ចូលទាំងករណី "ស្ងៀមស្ងាត់"ចំនួន ៥ករណី

ខេត្តកណ្តាល មាន៨ករណី ខេត្តកំពង់ធំ មាន៧ករណី ខេត្តកំពង់ចាម មាន៦ករណី ខេត្តកំពត មាន៤ករណី ខេត្តព្រៃវែង និងខេត្តតាកែវ មាន៣ករណី ខេត្តប៉ៃលិន មាន២ករណី ខេត្តកែប មាន១ករណី។



រូបទី ២: ចំនួននៃវិវាទដីធ្លី តាមបណ្តាខេត្តគិតត្រឹមឆ្នាំ២០១៦

តាមរយៈកិច្ចប្រជុំសមាជិកបណ្តាញសិទ្ធិដីធ្លី និងលំនៅឋានកាលពី ខែកុម្ភៈ ឆ្នាំ ២០១៧ ខេត្តនិមួយៗបានកំណត់ពីករណីវិវាទដែលមានលក្ខណៈប៉ះពាល់ខ្លាំង និងមានសមភាពពុំរ៉ៃ។ សម្រាប់ខេត្ត ខេត្តពោធិ៍សាត់បានលើកយកករណីវិវាទដីធ្លីរវាងប្រជាពលរដ្ឋចំនួន ២៣គ្រួសារ ជាមួយនិងក្រុមហ៊ុន MDS Import Export Co.,Ltd./ MDS Thmar Dar SEZ ដែលវិវាទនេះកើតមានតាំងពីឆ្នាំ ២០១០ រហូតមកដល់ពុំទាន់បានដោះស្រាយចប់ពេញលេញនៅឡើយ។ ក្នុងករណីនេះ បើតាមគម្រោងនិងជាដំណោះស្រាយពីថ្នាក់ខេត្តនិងថ្នាក់ជាតិ ប្រជាពលរដ្ឋរងផលប៉ះនឹងត្រូវប្តូរលំនៅឋានទៅរស់នៅទីតាំងថ្មីមួយ ដែលជាតំបន់មានគ្រាប់មីនមិនទាន់ផ្ទុះ ហើយថ្នាក់ខេត្តកំពុងតែពិភាក្សាអំពីការគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិការក្នុងការសម្អាត់មីនពីស្តាប័នជំនាញមុននឹងយកប្រជាពលរដ្ឋរងគ្រោះទៅរស់នៅទីនោះ។

៥.២.១ វិវាទដីធ្លីក្នុងខេត្តរតនគិរី

មានវិវាទដីធ្លី ចំនួន ៣១ករណី កំពុងកើតមាននៅក្នុងខេត្តរតនគិរី ជាខេត្តជាប់

លំដាប់ថ្នាក់ទីមួយមានវិវាទខ្ពស់ជាងបណ្តាខេត្ត និងរាជធានីនៃប្រទេសកម្ពុជា។ វិវាទាំងនោះកើតមានក្នុងស្រុកចំនួន៧ មានដូចជា ស្រុកអូយ៉ាដាវ មានចំនួន ៨ករណី ស្រុកអណ្តូង និងស្រុកបរកែវ មានចំនួន ៦ករណីដូចគ្នា ស្រុកលំជាត់ មានចំនួន៥ករណី ស្រុកកូនមុំ មានចំនួន ៣ករណី ស្រុកអូជុំ មានចំនួន ២ករណី និង ស្រុកបានលុង មានចំនួន១ករណី(ជាករណីដែលកើតឡើងក្នុងស្រុកចំនួន៣ គឺ ស្រុកបរកែវ ស្រុកអូរជុំ ស្រុកបានលុង រវាងប្រជាពលរដ្ឋ ក្រុមហ៊ុនតាយសេង(ស្វីសរ៉ាប់ប័រ)។ ក្នុងចំនោមវិវាទដីធ្លីទាំងនោះ មាន១៥ករណីជាវិវាទដែលបង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ក្រុមហ៊ុនទាំងនោះមានដូចជា ក្រុមហ៊ុនតាយសេង (ស្វីសរ៉ាប់ប័រ) ក្រុមហ៊ុនជាំងលី ក្រុមហ៊ុនហេងប្រាឌ័រ ក្រុមហ៊ុនហាង់អាញអូរយ៉ាដាវ ក្រុមហ៊ុនជីងសុងរី ក្រុមហ៊ុនAgrico., Coltd(បច្ចុប្បន្នលោក ឲ្យហាង់អាញលំជាត់) ក្រុមហ៊ុនម៉ែនសារ៉ុន(ហៅក្រុមហ៊ុនន៧២) ក្រុមហ៊ុន C R D(បច្ចុប្បន្នក្រុមហ៊ុនហាង់អាញ) ក្រុមហ៊ុនអេវឡេវប៊ីអឹមចញស្តុក ក្រុមហ៊ុនហ៊ាងអាញលំជាត់ ក្រុមហ៊ុន៧កមការជារី ក្រុមហ៊ុនរ័ត្នសាខន។ ចំណែកឯ វិវាទចំនួន៦ករណីទៀត បង្ករឡើងដោយសារការកាប់ទន្ទ្រានទៅដីព្រៃបំរុងទុករបស់រដ្ឋនិងដីសហគមន៍ វិវាទចំនួន៣ករណីបង្ករឡើងដោយការប្រើអំណាចរំលោភយកដី វិវាទចំនួន២ករណីបង្ករឡើងដោយសារឈ្មួញខិលខូច។ វិវាទចំនួន១ករណីដូចៗគ្នា បង្ករឡើងដោយសារការទិញលក់ដីសម្បហាភាពសហគមន៍ជនជាតិដើមភាគតិច ការចេញប័ណ្ណកម្មសិទ្ធិលើដីពលរដ្ឋដែលរស់នៅជាក់ស្តែងទៅឲ្យអ្នកដទៃ សម្បទានរុករករ៉ែ ក្រុមហ៊ុនឯកជនឈ្មោះថា លី សុងីម ដែលជាក្រុមហ៊ុនឯកជនវិនិយោគលើដំណាំកៅស៊ូ។

វិវាទទាំង ៣១ករណីនោះបានប៉ពាល់ដល់ប្រជាពលរដ្ឋចំនួន ២,៥៩៩.០០ គ្រួសារ លើផ្ទៃដី១២,៨៧០.០០ ហិកតា។ វិវាទនិមួយៗបានប៉ះពាល់ដីជាច្រើនប្រភេទ ជាក់ស្តែង មានចំនួន ២៧ករណីប៉ះពាល់ដល់ដីកសិម្ម វិវាទចំនួន ២៦ករណីបានប៉ះពាល់ដល់ដីលំនៅឋាន វិវាទចំនួន ១៣ករណីប៉ះដល់ព្រៃសហគមន៍។



រូបភាពទី៤ : ចំនួនវិវាទតាមស្រុកនៅខេត្តរតនគិរី

៥.២.២ វិវាទដីធ្លីក្នុងរាជធានីភ្នំពេញ

វិវាទដីធ្លីចំនួន ២៩ករណី កើតឡើងនៅក្នុងខ័ណ្ឌចំនួន១១ មានដូចជា ខ័ណ្ឌឫស្សីកែវ មានចំនួន៧ករណី ខ័ណ្ឌដង្កោ និងខ័ណ្ឌមានជ័យ មានចំនួន៦ករណីដូចគ្នា។ ខ័ណ្ឌចំការមន ខ័ណ្ឌច្បារអំពៅ និងខ័ណ្ឌពោធិ៍សែនជ័យ មានចំនួន ២ករណីដូចៗគ្នា។ ខ័ណ្ឌជ្រោយចង្វា ខ័ណ្ឌដូនពេញ ខ័ណ្ឌ៧មករា មានចំនួន ១ករណីដូចៗគ្នា និង ១ករណីផ្សេងទៀតជាករណីដែលស្ថិតក្នុងខ័ណ្ឌច្រើនចូលគ្នា។

ករណីវិវាទទាំង ២៩គឺបានបង្ករដោយមូលហេតុផ្សេងៗគ្នាដូចជា តម្រូវការដីសម្រាប់លំនៅឋាន មានចំនួន៦ករណី ការរស់នៅលើដីរដ្ឋ មានចំនួន៥ករណី ការជួលជុលផ្លូវដែក ដោយគំរោងADB ការបិទផ្លូវប្រជាពលរដ្ឋ ការរៀបចំនិងស្តារប្រឡាយទឹកស្អុយ កិច្ចសន្យាជួលរយៈវែង ការអាងអំណាចរំលោភយកដីប្រជាពលរដ្ឋ មានចំនួន ២ករណីដូចគ្នា។ តំបន់អភិវឌ្ឍន៍របស់រដ្ឋ ការតាំងលំនៅ

ហានមិនរៀបរយលើដីបឹងក្នុងឆ្នាំ១៩៩៨ ការប្រើប្រាស់លិខិតក្លែងក្លាយតាមរយៈផ្តល់សេចក្តីប្រកាសដោយភូតកុហក ការលក់ដូរដីដែលមិនគោរពទៅតាមកិច្ចសន្យាកក់ ការអភិវឌ្ឍន៍ផ្លូវល្បឿនលឿន ការអភិវឌ្ឍន៍ឡើងវិញនូវសំណង់អាគារចាស់ ការអភិវឌ្ឍន៍ក្រុងរណប គម្រោងពង្រីកព្រលានយន្តហោះ វិវាទលើដីវត្តទិញលក់(ដីរួម) មានចំនួន ១ករណីដូចៗគ្នា។

វិវាទទាំង២៩ករណីនេះ ប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ៥,៤០២.០០ គ្រួសារ លើផ្ទៃដីទំហំ ៣,៧២៤.៨១ហិកតា ដែលជាដីលំនៅឋាន។ មានវិវាទចំនួន២ដែលកើតឡើងតាំងពីឆ្នាំ១៩៩៨ និងបន្តរហូតមកដល់បច្ចុប្បន្ន ជាក់ស្តែងករណីលេខ ១៧៩៤ ជាវិវាទរវាងប្រជាពលរដ្ឋ ៨០០គ្រួសារ ជាមួយ លោក វរៈសុត្តា លើផ្ទៃដីប្រមាណជា ១៧ហិកតា ស្ថិតក្នុងភូមិទ្រា សង្កាត់ស្នឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ។ ករណីនេះបានឆ្លងកាត់ការដោះស្រាយជាច្រើនលើកច្រើនសារមកហើយ នៅដំណាក់កាលបច្ចុប្បន្ននេះដើមបណ្តឹងបានដាក់សំអាងទៅតុលាការកំពូល និងតុលាការកំពូលបានកាត់ឱ្យសាលាឧទ្ធរណ៍កាត់ក្តីសារជាថ្មី ក្រោយមកក៏មានការចុះវាស់វែងដោយមន្ត្រីជំនាញសុរិយោដី ហើយបានធ្វើរបាយការណ៍ទៅខាងសាលាឧទ្ធរណ៍រួចរាល់ហើយ និងកំពុងរងចាំការសម្រេចជាថ្មីពីសាលាឧទ្ធរណ៍។

សម្រាប់រាជធានីភ្នំពេញក្នុងឆ្នាំ២០១៦ មានករណីកើតថ្មីចំនួន ៤ករណីដែលបណ្តាលមកពីការរៀបចំនិងស្តារប្រឡាយទឹកស្អុយដើម្បីរំដោះទឹកចេញពីរាជធានីភ្នំពេញ ការរៀបចំអភិវឌ្ឍន៍សំណង់អាគារចាស់ ការអភិវឌ្ឍន៍ផ្លូវដែកជាដើម។ ជាក់ស្តែងករណីបណ្តាលមកពីការរៀបចំការអភិវឌ្ឍន៍សំណង់អាគារចាស់បានសាងសង់ក្នុងឆ្នាំ ១៩៦៣ គិតដល់បច្ចុប្បន្នមានអាយុកាលប្រមាណជា ៥៣ឆ្នាំ អាគារមានសភាពទ្រុតទ្រោម ការរស់នៅរបស់ប្រជាពលរដ្ឋមានភាពចង្អៀត។ អាគារនេះប្រជាពលរដ្ឋជាង ៤៩៣គ្រួសារកំពុងរស់នៅ រដ្ឋាភិបាល

តាមរយៈក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ កំពុងធ្វើការពិភាក្សាគ្នា ក្នុងការអភិវឌ្ឍន៍អាគារនេះទៅជាអាគារទំនើបមានកំពស់ ២១ជាន់ គម្រោងនេះ គឺជាការវិនិយោគរបស់ក្រុមហ៊ុនជប៉ុន Arakawa ក្នុងទឹកប្រាក់ចំនួន ៧០ ទៅ ៨០លានដុល្លា ដោយផ្តល់ជាកន្លែងស្នាក់នៅដល់ប្រជាពលរដ្ឋចំនួន ៥ជាន់ ហើយក្រុមហ៊ុននឹងក្លាយជាម្ចាស់កម្មសិទ្ធលើអាគារចាប់ពីជាន់ទី ៩ឡើងទៅ។ ប៉ុន្តែគម្រោងនេះស្ថិតក្នុងដំណាក់កាលនៃការពិភាក្សានៅឡើយរវាងប្រជាពលរដ្ឋ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ព្រមទាំងភាគីក្រុមហ៊ុន។ សម្រាប់ដំណាក់កាលនៃការសាងសង់ខាងមុខប្រជាពលរដ្ឋនឹងត្រូវស្នាក់នៅក្នុង សំណង់បណ្តោះអាសន្នដែលក្រសួងគ្រោងនឹងរៀបចំនៅក្នុងសង្កាត់ទឹកថ្លា រាជធានីភ្នំពេញ ដែលអាចចំណាយពេល៣ឆ្នាំ។



រូបភាពទី ៥: ចំនួនវិវាទ តាមខណ្ឌនៅរាជធានីភ្នំពេញ

៦. វិវាទដីធ្លីដែលបានដោះស្រាយ គិតតាមឆ្នាំ

ក្នុងឆ្នាំ២០១៦ មានវិវាទដីធ្លីសរុប ចំនួន ៣៨២ករណី បានធ្វើការតាមដាន និង

ផ្សៀងផ្ទាត់នៅទូទាំងប្រទេស ក្នុងនោះមានវិវាទចំនួន៥៨ករណីត្រូវបានដោះស្រាយចប់ពេញលេញទាំងស្រុង វិវាទចំនួន៣ករណីត្រូវបានដោះបង់ចោល វិវាទចំនួន៥ករណី មានសភាពស្ងៀមស្ងាត់ វិវាទចំនួន១៦៥ករណីដោះស្រាយបានមួយផ្នែក វិវាទចំនួន១០៦ករណីស្ថិតក្នុងដំណើរការនៃការដោះស្រាយ វិវាទចំនួន៤៥ករណីមិនទាន់មានចំណាត់ការក្នុងការដោះស្រាយ។

ចំនួនតួលេខនៃករណីវិវាទបានដោះស្រាយចប់ពេញលេញទាំងស្រុងក្នុងឆ្នាំ ២០១៦ ចំនួន៥៨ករណីនេះ គឺមានការកើនឡើងទ្វេដងបើធៀបទៅនឹងតួរលេខនៅឆ្នាំ២០១៥ មានចំនួន ២១ករណី។ ប៉ុន្តែចំនួននេះទាបជាងវិវាទដោះស្រាយចប់ពេញលេញទាំងស្រុងក្នុងឆ្នាំ ២០១៤ មានចំនួន ៦៨ករណី ឆ្នាំ២០១៣ មានចំនួន ៨១ករណី និងឆ្នាំ២០២១២ មានចំនួន ១០៨ករណី។



រូបទី ៦: ទំនោរនៃការដោះស្រាយករណីវិវាទដីធ្លីតាមបណ្តាឆ្នាំ

វិវាទដីធ្លីទាំង៥៨ករណី បានដោះស្រាយចប់ពេញលេញទាំងស្រុងនៅក្នុងឆ្នាំ ២០១៦នេះ បានកើតឡើងនៅក្នុងឆ្នាំផ្សេងៗគ្នា ក្នុងនោះវិវាទខ្លះកើតឡើងក្នុងឆ្នាំមុនឆ្នាំ២០០០ មានចំនួន២ករណី វិវាទកើតឡើងក្នុងឆ្នាំ២០០០ មានចំនួន២ករណី វិវាទកើតឡើងក្នុងឆ្នាំ២០០២ មានចំនួន២ករណី វិវាទកើតឡើងក្នុងឆ្នាំ២០០៤ មានចំនួន ១ករណី វិវាទកើតឡើងក្នុងឆ្នាំ២០០៧ មានចំនួន៥ករណី វិវាទកើតឡើងក្នុងឆ្នាំ

២០០៨ ឆ្នាំ២០០៩ និងឆ្នាំ២០១០ មានចំនួន២ករណីដូចគ្នា វិវាទកើតឡើងក្នុងឆ្នាំ ២០១១ មានចំនួន៦ករណី វិវាទកើតឡើងក្នុងឆ្នាំ២០១២ មានចំនួន៣ករណី វិវាទកើតក្នុងឆ្នាំ២០១៣ មានចំនួន៥ករណី វិវាទកើតឡើងក្នុងឆ្នាំ២០១៤ មានចំនួន៦ករណី វិវាទកើតឡើងក្នុងឆ្នាំ២០១៥ និងឆ្នាំ២០១៦ មានចំនួន១០ករណីដូចគ្នា។



រូបទី ៧: ចំនួនករណីវិវាទដីធ្លីតាមឆ្នាំនិមួយៗបានដោះស្រាយក្នុងឆ្នាំ២០១៦

ចំពោះលទ្ធផលនៃការដោះស្រាយនៃវិវាទទាំង ៥៨ករណីនេះ មានលក្ខណៈផ្សេងៗគ្នាទៅតាមករណីនិមួយៗ។ វិវាទដីធ្លីចំនួន ៧ករណី លទ្ធផលនៃការដោះស្រាយបានដល់ភាគីទាំងសងខាងនៃវិវាទ វិវាទចំនួន ៣៦ករណី លទ្ធផលនៃការដោះស្រាយបានដល់ភាគីដើមបណ្តឹង វិវាទចំនួន ១០ករណី លទ្ធផនៃការដោះស្រាយបានដល់ភាគីចុងបណ្តឹង វិវាទចំនួន ៤ករណី លទ្ធផលនៃការដោះស្រាយតាមរយៈសំណង និងវិវាទចំនួន ១ករណី ការដោះស្រាយដោយភ្ជាប់ជាមួយនិងកិច្ចសន្យា។



រូបទី ៨: លទ្ធផលនៃដំណោះស្រាយវិវាទនិមួយៗក្នុងឆ្នាំ២០១៦

សមាសភាពនៃគូរភាគីវិវាទ ទាំង៥៨ករណី ដែលបានដោះស្រាយចប់ពេញទាំងស្រុងក្នុងឆ្នាំ២០១៦ មានដូចជា ភាគីវិវាទជាប្រជាពលរដ្ឋជាប្រជាកសិករមានមានចំនួន៣៦ករណី ភាគីវិវាទជាក្រុមហ៊ុន មានចំនួន១២ករណី ភាគីវិវាទជាមន្ត្រីភូមិ និងជាមន្ត្រីខេត្ត មានចំនួន៥ករណីដូចគ្នា។ ភាគីវិវាទជាមន្ត្រីស្រុក ប្រជាពលរដ្ឋជនជាតិដើមភាគតិច និងជាទាហាន មានចំនួន៣ករណីដូចគ្នា។ ភាគីវិវាទជាមន្ត្រីឃុំ មានចំនួន១ករណី និងមានមន្ត្រីដែលមិនស្គាល់ពីតួនាទី មានចំនួន៥ករណី។

ចំណែកឯមូលហេតុដែលបង្កឲ្យមានវិវាមានដូចជា ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចមានចំនួន ១២ករណី ការអាងអំណាចការរំលោភយកដីប្រជាពលរដ្ឋ និងវិវាទលើដីរដ្ឋ មានចំនួន៧ករណីដូចគ្នា។ តម្រូវការដីសម្រាប់ដាំដុះ មានចំនួន៤ករណី វិវាទពាក់ព័ន្ធនិងការផ្តល់សម្បទានដីសង្គមកិច្ច ការរំលោភដីរួមរបស់ភូមិ និងតម្រូវការដីលំនៅឋាន មានចំនួន៣ករណីដូចគ្នា និងវិវាទពាក់ព័ន្ធជាមួយទាហាន ចំនួន២ករណី។ ការអភិវឌ្ឍន៍និងការសាង់សង់ប្រឡាយទឹក ការរំលោភយកដីវត្ត ការរំលោភ

យកអាងស្តុកទឹកធ្វើជាកម្មសិទ្ធ ការធ្វើផ្លូវចូលទៅទីតាំងក្រុមហ៊ុនឯកជន ការសាងសង់ផ្ទះរំលោភលើផ្លូវសាធារណៈ គំរោងសាងសង់ផ្លូវដែក ការរំលោភដីព្រៃសហគមន៍ ការធ្វើចំណូលស្រុក វិវាទដោយសារព្រំរដ្ឋបាលឃុំ ការរំលោភយកដីកប់ខ្មោចរបស់ជនជាតិដើមភាគតិចធ្វើជាកម្មសិទ្ធិ ការបិទផ្លូវប្រជាពលរដ្ឋ មានចំនួន១ករណីដូចគ្នា និង៦ករណីទៀតមិនមានពត៌មានមូលហេតុបង្កវិវាទ។

៦.១ ស្ថាប័នទទួលពាក្យបណ្តឹង

ភាគីវិវាទ ទាំងអ្នកកាន់កាប់ដីដើម និងភាគីទីពីរ បានដាក់ពាក្យបណ្តឹងរបស់ពួកគេទៅស្ថាប័នរដ្ឋដែលពាក់ព័ន្ធ និងស្ថាប័នតុលាការ។ ក្នុងចំណោមវិវាទ ចំនួន ៣៨២ករណី មានបណ្តឹងសរុបចំនួន ១,០៥១.០០បណ្តឹង ដែលកត់ត្រាក្នុងមូលដ្ឋានទិន្នន័យរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។ ពាក្យបណ្តឹងទាំងនោះ បានជូនទៅអាជ្ញាធរមូលដ្ឋានឃុំ/សង្កាត់និងស្រុក/ខ័ណ្ឌ ចំនួន២៣២បណ្តឹង សាលារាជធានី/ខេត្ត ចំនួន១៩១បណ្តឹង រដ្ឋសភា ចំនួន៦៧បណ្តឹង ខុទ្ទការល័យនាយករដ្ឋមន្ត្រី ចំនួន៥១បណ្តឹង ក្រសួងមហាផ្ទៃ ចំនួន៣៨បណ្តឹង អាជ្ញាធរដោះស្រាយវិវាទដីធ្លីថ្នាក់ជាតិ ចំនួន២៥បណ្តឹង ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ចំនួន២៥បណ្តឹង ទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន១៨បណ្តឹង ព្រះបរមរាជវាំង ចំនួន៥បណ្តឹង។ គណៈកម្មការសុរិយោដីទាំងបីថ្នាក់ដូចជា គណៈកម្មការសុរិយោដីស្រុក/ខ័ណ្ឌ ចំនួន៣៤បណ្តឹង គណៈកម្មការសុរិយោដីខេត្ត ចំនួន២៨បណ្តឹង គណៈកម្មការសុរិយោដីជាតិ ចំនួន៧បណ្តឹង។ ស្ថាប័នតុលាការទាំងបីថ្នាក់ សាលាដំបូងរាជធានី/ខេត្ត ចំនួន៩៨បណ្តឹង សាលាឧទ្ធរណ៍ ចំនួន៣២បណ្តឹង តុលាការកំពូលខេត្ត/រាជធានី ចំនួន១៨បណ្តឹង។ ផ្សេងៗទៀត ចំនួន១៨២បណ្តឹង ក្នុងនោះមានដូចជា មន្ត្រីជំនាញរដ្ឋាបាលព្រៃឈើ រដ្ឋបាលជល ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ អង្គភាពប្រឆាំងអំពើពុករលួយ អង្គការសង្គមសីវិល ក្រសួងការពារជាតិ តុលាការអង្គគ្លេស និងសហគមន៍អ៊ឺរ៉ុប។

ជាសរុប មានពាក្យបណ្តឹងចំនួន ១៤៨បណ្តឹង ដែលគួរភាគីវិវាទសម្រេចចិត្ត បានដាក់ទៅប្រព័ន្ធតុលាការ និង បណ្តឹងចំនួន ៩០៣បណ្តឹងបានដាក់ទៅស្ថានប័ន ក្រៅប្រព័ន្ធតុលាការ។



រូបទី ៩៖ ស្ថាប័នដែលទទួលពាក្យបណ្តឹង

៦.២ ដំណើរការដោះស្រាយ

សម្រាប់ឆ្នាំ២០១៦ វិវាទទាំង ៣៨២ករណី មានវិវាទចំនួន ៣២៩ករណី ស្មើរនឹង៨៦.១២ភាគរយ បានឆ្លងកាត់ដំណើរការដោះស្រាយ ដោយក្នុងនោះ ៥៨ករណីបានដោះស្រាយចប់ពេញលេញទាំងស្រុង ១៦៥ករណីដោះស្រាយបានមួយផ្នែក ១០៦ករណីកំពុងដំណើរការដោះស្រាយ។ វិវាទទាំងនោះ បានដាក់ពាក្យបណ្តឹងជូន

ទៅស្ថានប័នផ្សេងៗគ្នា ដូចជា អាជ្ញាធរមូលដ្ឋាន សាលាខេត្ត គណៈកម្មការសុរិយោដី ខេត្ត គណៈកម្មការសុរិយោដីថ្នាក់ជាតិ នាយករដ្ឋមន្ត្រី តុលាការទាំងបីកម្រិត (សាលាដំបូងរាជធានី/ខេត្ត សាលាឧទ្ធរណ៍ និងតុលាការកំពូល) ក្រសួងការពារជាតិ គណៈកម្មការចំរុះថ្នាក់ខេត្ត មន្ទីកសិកម្មរុក្ខាប្រមាញ់និងនេសាទ ក្រសួងបរិស្ថាន ក្រសួងរៀបចំដែនដី ជាដើម។ ប៉ុន្តែលទ្ធផលនៃការដោះស្រាយវិវាទដីធ្លី គឺខុសៗគ្នា ពីករណីមួយ ទៅករណីមួយ។



រូបទី ១០៖ ស្ថានភាពនៃករណីវិវាទ

ចំពោះវិវាទដែលបានដោះស្រាយចប់ពេញលេញទាំងស្រុងចំនួន ៥៨ករណី ក្នុងនោះមានវិវាទ ៧ករណី លទ្ធផលនៃការដោះស្រាយបានដល់ភាគីទាំងសងខាងនៃវិវាទ វិវាទចំនួន ៣៦ករណី លទ្ធផលនៃការដោះស្រាយបានដល់ភាគីដើមបណ្តឹង វិវាទចំនួន ១០ករណី លទ្ធផនៃការដោះស្រាយបានដល់ភាគីចុងបណ្តឹង វិវាទចំនួន ៥ករណី លទ្ធផលនៃការដោះស្រាយតាមរយៈសំណង និងវិវាទចំនួន ១ករណី ការ

ដោះស្រាយដោយភ្ជាប់ជាមួយនិងកិច្ចសន្យា។



រូបទី ១១៖ លទ្ធផលនៃករណីវិវាទដែលបានដោះស្រាយ

នៅក្នុងដំណើរការនៃការដោះស្រាយ ចំពោះករណីវិវាទដែលបានដោះស្រាយចប់ពេញលេញទាំងស្រុងទាំង ៥៨ករណី ឯកសារដែលប្រើប្រាស់ជាការសំអាងក្នុងការទាមទារដីដោយគូរភាគីវិវាទ រួមមាន ការរស់នៅនិងកាន់កាប់ជាក់ស្តែង មានចំនួន ១១ករណី លិខិតទទួលស្គាល់ពីអាជ្ញាធរភូមិ/ឃុំ មានចំនួន៩ករណី កិច្ចសន្យាផ្តល់ដីសម្បទាន់ដីសេដ្ឋកិច្ច មានចំនួន៧ករណី។ វិញ្ញាបណ្ណប័ត្រសំគាល់ម្ចាស់អចលនៈវត្ថុ ការសំអាងលើដីរបស់រដ្ឋ និងស.ជ.ណផ្តល់ដី មានចំនួន២ករណីដូចគ្នា។ សំអាងលើការចងក្រងជាក្រុមសាមគ្គី ប្លង់រឹង ពាក្យស្នើរសុំអភិវឌ្ឍន៍ដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ពាក្យស្នើសុំកាន់កាប់ដីធ្លី បង្កាន់ដៃកាន់កាប់ដីធ្លី ផែនទីព្រាងដីសមូសភាព សហគមន៍ជនជាតិដើមភាគតិចដើម្បីរងចាំការចុះបញ្ជីរបស់ក្រសួង ប័ណ្ណស្លាប់មាន់សៀវភៅគ្រួសារ និងឯកសារសំអាងថាជីបរិស្ថាន មានចំនួន១ករណីដូចគ្នា និង១៦ករណីទៀតមិនមានព័ត៌មាន។



រូបទី ១២៖ ឯកសារដែលប្រើប្រាស់សម្រាប់ការទាមទារយកដីដោយភាគីនៃវិវាទដីធ្លី

ដោយឡែកចំពោះវិវាទចំនួន៣ករណី ត្រូវបានដោះបង់ចោល ករណីទី១ គឺដោយសារដើមបណ្តឹងស្លាប់ ហើយអ្នកបន្តជាតំណាងដើមបណ្តឹងមិនមានឆន្ទៈនៅក្នុងការប្តឹង ដោយតែងតែមិនមកជួបមេធាវីតាមការណាត់ជួប មានចំនួន១ករណី (លេខ២៣៣១)។ ករណីទី២ គឺអាជ្ញាធរឃុំបានប្តឹងតំណាងប្រជាពលរដ្ឋទៅតុលាការ ហើយតុលាការបានកោះហៅតំណាងទៅបំភ្លឺ ដោយចោទថាប្រជាពលរដ្ឋបានរំលោភយកដីសាធារណៈរបស់រដ្ឋ ក្រោយមកដោយជួបផលលំបាក ពលរដ្ឋបានដកខ្លួនចេញពីដីកើតហេតុ ករណី(លេខ១៧៥៧)។ ករណីទី៣ គឺប្រជាពលរដ្ឋជាដើមបណ្តឹងធ្លាប់ត្រូវអាជ្ញាធរបាញ់គំរាមកំហែងបានធ្វើចំណាកស្រុកទៅក្រៅខេត្ត (ខេត្តរតនគីរី)អស់ លែងមានអ្នកណាចេញមុខក្នុងការប្តឹងទាមទារ ករណី (លេខ២០២០)។

ចំពោះវិវាទ ៥ករណីមានសភាពស្ងៀមស្ងាត់មិនមានដំណើការ ឬមិនមានការវិវឌ្ឍន៍ដែលជាសញ្ញានៃការឈានទៅរកការដោះស្រាយនោះ ដោយសារតែ ករណីខ្លះក្រោយពីមានការប្តឹងផ្តល់ឆ្លងកាត់ការកោះហៅរបស់តុលាការមួយលើក ឬពីរលើកមក មានការព្រមផ្តល់ជាសំណងពីភាគីចុងបណ្តឹងតែត្រូវបានភាគីដើមបណ្តឹងដិសេធ តែមិនមានសកម្មភាពប្តឹងបន្តដោយភាគីដើមបណ្តឹង ចំណែកភាគីចុងបណ្តឹងក៏មិនបានបន្តសកម្មភាពអ្វីទៅលើដីទំនាស់ និងវិវាទខ្លះដោយសារតែភាគីវិវាទទាំងសងខាងមិនមានសកម្មភាពទៅលើដីទំនាស់ក៏មិនមានការបន្តការប្តឹងផ្តល់អ្វីទៀតជាដើម។

នៅក្នុងការទាមទារអោយមានដំណោះស្រាយទាំងករណីបានដោះស្រាយចប់ពេញលេញទាំងស្រុង ករណីដោះស្រាយដោយផ្នែក ករណីស្ថិតក្នុងដំណើការនៃការដោះស្រាយ និងករណីដែលមិនទាន់មានដំណើរដំណើរការដោះស្រាយ ពលរដ្ឋរងផលប៉ះពាល់បានស្វះស្វែងរកការដោះស្រាយតាមគ្រប់លទ្ធភាពដែលមាន។ ការប្រមូលផ្តុំគ្នាឡើងមកតវ៉ានៅតាមសាលាឃុំ សាលាស្រុក សាលាខេត្ត តាមក្រសួង និងស្ថាប័ន នានា គឺជាមធ្យោបាយមួយក្នុងចំនោមមធ្យោបាយដទៃៗទៀតសម្រាប់ជួយជម្រុញឲ្យមានដំណើរការដោះស្រាយពីស្ថាប័នដែលទទួលបន្ទុក ជាក់ស្តែងក្នុងឆ្នាំ ២០១៦ មានការប្រជុំតវ៉ា និងដាក់ពាក្យបណ្តឹងតាមស្ថាប័នខាងលើចំនួន ១៧៦ដង។ ក្នុងនោះមាការតវ៉ានៅលើដីទំនាស់ ចំនួន៤២ដង សាលាខេត្តនៃបណ្តាខេត្ត ចំនួន៤០ដង សាលារាជធានីភ្នំពេញ ចំនួន២២ដង ក្រសួង ដ.ន.ស ចំនួន១៨ដង រដ្ឋសភាជាតិ ចំនួន១៤ដង សាលាឃុំ/សង្កាត់តាមបណ្តាខេត្ត/ក្រុង ចំនួន១០ដង សាលាស្រុកនៃបណ្តាខេត្ត ចំនួន៧ដង សហភាពអឺរ៉ុប ចំនួន៥ដង ខុទ្ទការល័យនាយករដ្ឋមន្ត្រី ចំនួន៤ដង សាលាឧទ្ធរណ៍តាមបណ្តាខេត្ត ចំនួន២ដង ភូមិតាមបណ្តាខេត្ត ចំនួន២ដង ក្រសួងយុត្តិធម៌ ចំនួន២ដង ក្រសួងសាធារណៈ ចំនួន២ដង ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ចំនួន១ដង ពន្ធាគារព្រៃស ចំនួន១ដង អង្គភាពប្រឆាំងអំពើពុករលួយ ចំនួន១ដង អង្គការសហគមន៍កម្ពុជា ចំនួន១ដង ក្រសួងមហាផ្ទៃ ចំនួន១ដង ទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន១ដង។

៦.៣ ស្ថាប័នដោះស្រាយវិវាទដីធ្លីក្នុងឆ្នាំ២០១៦

វិវាទដីធ្លីសរុបដែលបានដោះស្រាយចប់ពេញលេញទាំងស្រុងក្នុងឆ្នាំ ២០១៦ មានចំនួន ៥៨ករណី បានកើតឡើងនៅក្នុងខេត្ត ចំនួន១៩ ក្នុងមានខេត្តកំពង់ចាម និងខេត្តកំពង់ធំ ដោះស្រាយចប់ពេញលេញទាំងស្រុងចំនួន៧ករណីដូចគ្នា។ ខេត្តស្វាយរៀង ដោះស្រាយចប់ពេញលេញទាំងស្រុងចំនួន៥ករណី។ ខេត្តពោធិ៍សាត់ និងខេត្តព្រះវិហា ដោះស្រាយចប់ពេញលេញទាំងស្រុងចំនួន៤ករណីដូចគ្នា។ ខេត្ត

កំពង់ឆ្នាំង ខេត្តកំពត ខេត្តមណ្ឌលគិរី ខេត្តប៉ៃលិន ខេត្តព្រៃវែង និងខេត្តតាកែវដោះស្រាយចប់ពេញលេញទាំងស្រុងចំនួន៣ករណីដូចគ្នា។ ខេត្តកោះកុង ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ ដោះស្រាយចប់ពេញលេញទាំងស្រុងចំនួន២ករណីដូចគ្នា ហើយ ខេត្តបន្ទាយមានជ័យ ខេត្តកណ្តាល និងក្រចេះ ដោះស្រាយចប់ពេញលេញទាំងស្រុងចំនួន១ករណីដូចៗគ្នា។



រូបទី១៣៖ ករណីវិវាទតាមខេត្តនិមួយៗបានដោះស្រាយចប់ពេញលេញទាំងស្រុងក្នុងឆ្នាំ២០១៦

លទ្ធផលទាំងនេះកើតចេញពីការខិតខំប្រឹងប្រែងរបស់អាជ្ញារពាក់ព័ន្ធដូចជាសាលាខេត្ត មានចំនួន១៣ករណី អាជ្ញាធរមូលដ្ឋានឃុំនិងស្រុក មានចំនួន១២ករណី

ក្រុមការងារខេត្តនិងមន្ទីពាក់ព័ន្ធ មានចំនួន៨ករណី រាជរដ្ឋាភិបាល មានចំនួន៥ករណី។ តុលាការ និងគូរភាគីនៃវិវាទ មានចំនួន៤ករណីដូចគ្នា។ គណៈកម្មការសុរិយោដី មានចំនួន៣ករណី មន្ទីរបរិស្ថាន មានចំនួន២ករណី។ ទីស្តីការគណៈរដ្ឋមន្ត្រី ការបញ្ចប់ដោយចុងចម្លើយនិងដើមបណ្តឹងស្លាប់ទាំងអស់ មន្ទីរសុរិយោដីខេត្ត រដ្ឋបាលព្រៃឈើ ក្រសួងរៀបចំដែនដី និងព្រះបរមរាជវាំង មានចំនួន១ករណីដូចគ្នា ហើយករណីវិវាទចំនួន២មិនមានព័ត៌មានពីស្ថាប័នដោះស្រាយ។

គួរកត់សម្គាល់ នៅក្នុងចំណោមវិវាទទាំង ៥៨ករណី បានដោះស្រាយចប់ពេញលេញទាំងស្រុងនេះ មានវិវាទ ចំនួន១៥ករណីបានដាក់ពាក្យបណ្តឹងទៅស្ថាប័នតុលាការ ប៉ុន្តែមានតែវិវាទចំនួន ៤ករណីប៉ុណ្ណោះដោះស្រាយបញ្ចប់ដោយប្រព័ន្ធតុលាការ។ ចំណែកវិវាទ ១១ករណី ក្នុងចំណោមវិវាទទាំង ១៥ករណីនេះដោះស្រាយដោយ ស្ថាប័នផ្សេងៗដូចជា រាជរដ្ឋាភិបាល ទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាការជាតិដោះស្រាយវិវាទដីធ្លីអាជ្ញាធរខេត្ត អភិបាលស្រុក អាជ្ញាធរឃុំ ការសម្រប់សម្រួលដោយអង្គការ Adhoc គូរភាគីវិវាទសម្របសម្រួលគ្នាបញ្ចប់ជម្លោះ។



រូបទី១៤៖ ស្ថាប័នដែលដោះស្រាយវិវាទដីធ្លីក្នុងឆ្នាំ២០១៦

៧. គ្រួសាររងផលប៉ះពាល់ពីវិវាទដីធ្លី

វិវាទដីធ្លីចំនួន ៣១៤ករណី[12] កំពុងបន្តរងចាំដំណោះស្រាយ បានប៉ះពាល់ដល់ប្រជាពលរដ្ឋ ចំនួន ៥៤,៥០៧.០០គ្រួសារ ប៉ុន្តែមានវិវាទដីធ្លីចំនួន ២៦ករណី មិនមានព័ត៌មានអំពីគ្រួសារដែលរងផលប៉ះពាល់ពីវិវាទ។

ល.រ	ខេត្ត	#ករណីវិវាទដីធ្លីដែលកំពង់បន្តក្នុងឆ្នាំ២០១៥	#គ្រួសាររងផលប៉ះពាល់	ល.រ	ខេត្ត	#ករណីវិវាទដីធ្លីដែលកំពង់បន្តក្នុងឆ្នាំ២០១៥	#គ្រួសាររងផលប៉ះពាល់
១	បន្ទាយមានជ័យ	២៨	៣១១៦	១៤	ប៉ៃលិន	២	៤០០
២	បាត់ដំបង	១៨	៩៥៦	១៥	រាជធានីភ្នំពេញ	២៨	៤៨៩៣
៣	កំពង់ចាម	៦	២៣១៦	១៦	ព្រះសីហនុ	១៩	២០៩០
៤	កំពង់ឆ្នាំង	៩	២៦២៨	១៧	ព្រះវិហារ	១៨	២៦៧២
៥	កំពង់ស្ពឺ	១៨	២៦១៦	១៨	ព្រៃវែង	២	៣៦៦៣
៦	កំពង់ធំ	៧	៣៥៨	១៩	ពោធិ៍សាត់	១៦	១៥៦៩
៧	កំពត	៨	១២៧១	២០	រតនគិរី	៣០	២៨១៩
៨	កណ្តាល	៨	១១៩០	២១	សៀមរាប	២១	២២២
៩	កែប	១	២១	២២	ស្ទឹងត្រែង	១០	៨៦៨
១០	កោះកុង	១៣	១៨៥៧	២៣	ស្វាយរៀង	១២	១៥៨៩
១១	ក្រចេះ	១០	៣២៨៧	២៨	តាកែវ	៣	១៧៧
១២	មណ្ឌលគិរី	១៩	៨៨១៦	២៥	ត្បូងឃ្មុំ	៩	១៥៦៧
១៣	ឧត្តរមានជ័យ	១១	៦៧៩០	**សរុប**		**៣១៨**	**៥៤៥០៧**

តារាងទី១៖ គ្រួសាររងផលប៉ះពាល់ដោយសារវិវាទដីធ្លីតាមបណ្តាខេត្ត

ប្រជាពលរដ្ឋរងផលប៉ះពាល់ពីវិវាទដីធ្លីច្រើនជាងគេ គឺខេត្តឧត្តរមានជ័យ ដោយមានចំនួន ៦,៧៩០.០០ គ្រួសារ ចំនួនដ៏ច្រើននេះបណ្តាលមកពីវិវាទភាគច្រើនជាវិវាទកើតឡើងក្នុងតំបន់សហគមន៍ព្រៃឈើដែលមានសមាជិកសហគមន៍ច្រើន ហើយសិទ្ធិនៃការប្រើប្រាស់ ចាត់ចែង និងការអាស្រ័យផលរបស់ប្រជាពលរដ្ឋជាសមាជិកសហគមន៍ មានលក្ខណៈខុសពីកម្មសិទ្ធិឯកជនដទៃទៀត។ ជាក់ស្តែងសម្រាប់ខេត្តនេះ មានសហគមន៍ព្រៃឈើចំនួន ៥សហគមន៍ក្នុងចំណោមសហគមន៍

[12] ចំនួននេះមិនរាប់បញ្ចូលនូវករណី “ស្បៀមស្ងាត់”ចំនួន ៥ករណីទេ

ព្រៃឈើ ១៣សហគមន៍ដែលទទួលបានកិច្ចព្រមព្រៀងសហគមន៍ពីរដ្ឋបាលព្រៃឈើ ក្នុងអំឡុងឆ្នាំ ២០០៨ និងឆ្នាំ២០០៩ ហើយកំពុងកើតមានវិវាទដីធ្លីជាមួយទាហាន ក៏ដូចជាក្រុមគ្រួសារទាហានដែលកំពុងរៀបចំបន្ទាយនៅក្នុងខេត្តនេះ។ សហគមន៍ព្រៃឈើទាំង៥នោះ មានដូចជា សហគមន៍ព្រៃឈើអណ្តូងបរ សហគមន៍ព្រៃឈើដុងបេង សហគមន៍ព្រៃឈើភ្នំដងរ៉ែកសំរ៉ែកព្រៃស្រស់ និងសហគមន៍រតនៈវុក្ខា។ វិវាទដីប៉ះពាល់ដល់ប្រជាពលរដ្ឋខ្ពស់ជាងគេក្នុងខេត្តនេះ គឺជាវិវាទរវាងសមាជិកសហគមន៍ព្រៃឈើរតនៈវុក្ខា ចំនួន ២០០០គ្រួសារ ជាមួយនឹងគ្រួសារទាហានដែលបានកាប់ទន្ទ្រាន់យកដីព្រៃសហគមន៍ធ្វើជាកម្មសិទ្ធិ លើផ្ទៃដីប្រមាណជា ៣,០០០.០០ ហិកតា ក្នុងចំនោមទំហំផ្ទៃដីសហគមន៍សរុបចំនួន១២,៨៧២.០០ ហិកតា វិវាទនេះកើតឡើងតាំងពីឆ្នាំ២០០៩ និងបន្តរីកកាន់តែធំឡើងៗរហូតមកដល់បច្ចុប្បន្ន។ សហគមន៍បានខិតខំប្រឹងប្រែងធ្វើការជូនដំណឹងទៅស្ថាប័នទទួលបន្ទុកគឺ ខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្ត ព្រមទាំងអាជ្ញាធរខេត្តជារឿយៗដើម្បីទទួលបានកិច្ចអន្តរាគមន៍ ប៉ុន្តែនៅតែមិនទាន់ទទួលបានដំណោះស្រាយ បច្ចុប្បន្នសហគមន៍កំពុងតែរៀបចំឯកសារបន្ថែមដើម្បីមកដាក់ពាក្យបណ្តឹងនៅក្រសួងកសិកម្ម និងរដ្ឋបាលព្រៃឈើ។



រូបផែនទី ១៖ សហគមន៍ដែលកំពុងមានវិវាទនៅក្នុងខេត្តឧត្តរមានជ័យ

វិវាទមួយករណីទៀត កើតមាននៅក្នុងសហគមន៍ព្រៃឈើភ្នំដងរ៉ែកសំរ៉ែកព្រៃ

ស្រស់ មានសមាជិកសហគមន៍ចំនួន ១៥០០ គ្រួសារ កំពុងប្រឈមនឹងការបាត់បង់ដីព្រៃសហគមន៍ដោយសារតែអាជ្ញាធរមូលដ្ឋានហាក់មិនបានចូលរួមក្នុងការទប់ស្កាត់បទល្មើសព្រៃឈើ ក៏ដូចគ្នានឹងការកាប់ទន្ទ្រានដីព្រៃសហគមន៍ធ្វើកម្មសិទ្ធិ តែបែរជាបានចូលរួមចំណែកបង្ករឲ្យមានការកាប់ទន្ទ្រានដីព្រៃសហគមន៍ធ្វើជាកម្មសិទ្ធិកើតឡើងទៅវិញ ដោយបានការចេញបង្កាន់ឲ្យកាន់កាប់លើដីដែលបានកាប់ទន្ទ្រានពីសំណាក់អ្នកស្រុក និងកម្លាំងទាហានការពារព្រំដែននោះផងដែរ។ ការនេះធ្វើឲ្យប្រជាពលរដ្ឋជាសមាជិកសហគមន៍ទាំង ៤ភូមិបានធ្វើការប្តឹងទៅតុលាការ និងអាជ្ញាធរខេត្តនៅក្នុងខែ មករា ឆ្នាំ២០១៦។

ពលរដ្ឋការពារព្រៃសហគមន៍ចំនួន៤ភូមិប្តឹងពីចៅសង្កាត់ សង្កាត់រង និងមេភូមិមកអាជ្ញាធរ និងតុលាការរឿងបើកដៃឱ្យកាប់ព្រៃយកដី

Scanned by NGOF
30-January-2016
Rasmei Kampuchea

ពលរដ្ឋការពារព្រៃសហគមន៍ចំនួន៤ភូមិប្តឹងពីចៅសង្កាត់ សង្កាត់រង និងមេភូមិមកអាជ្ញាធរ និងតុលាការរឿងបើកដៃឱ្យកាប់ព្រៃយកដី

Scanned by NGOF
30-January-2016
Rasmei Kampuchea

បន្ទាប់ពីខេត្តឧត្តរមានជ័យ គឺរាជធានីភ្នំពេញ មានប្រជាពលរដ្ឋចំនួន ៤,៨៩៣.០០គ្រួសារ រងផលប៉ះពាល់ពីវិវាទចំនួន ២៩ករណី។ ករណីវិវាទប៉ះពាល់ប្រជាពលរដ្ឋច្រើនជាងគេក្នុងចំណោមវិវាទកើតឡើងក្នុងរាជធានីភ្នំពេញ គឺជាវិវាទរវាងប្រជពលរដ្ឋ ៨០០គ្រួសារ ជាមួយលោក វរៈ សេត្តា ដោយបានកើតឡើងតាំងពីឆ្នាំ១៩៩៨ លើផ្ទៃដីទំហំ ១៧ ហិចតា ជាដីលំនៅឋាន ស្ថិតក្នុងភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ។ រហូតមកដល់បច្ចុប្បន្នប្រជាពលរដ្ឋរងគ្រោះនៅតែបន្តទាមទារការដោះស្រាយ ហើយករណីនេះតុលាការកំពូលបានកាត់ឲ្យសាលាឧទ្ធរណ៍ធ្វើការកាត់ក្តីសាជាថ្មី។

៧.១ ប្រភេទដីដែលរងផលប៉ះពាល់ពីវិវាទដីធ្លី

វិវាទដីធ្លីមិនទាន់ដោះស្រាយចប់ពេញលេញទាំងស្រុង និងកំពុងរងចាំការដោះស្រាយទាំង ៣១៤ករណី បានគ្រប់ដណ្តប់លើផ្ទៃដីទំហំ ១,០៥២,៩៣៥.៩១ហិកតា ប៉ុន្តែមានករណីវិវាទចំនួន ៣៥ករណី ក្នុងចណោមវិវាទ៣១៤ករណី មិនមានព័ត៌មានអំពីទំហំដីវិវាទ។ វិវាទនិមួយៗអាចប៉ះពាល់ដល់ដីច្រើនប្រភេទផ្សេងៗគ្នា ជាក់ស្តែងមានវិវាទចំនួន ១៤៩ករណី បានប៉ះពាល់ដល់ដីចំការ វិវាទចំនួន ១០៨ករណីបានប៉ះដល់ដីភូមិ/ដីលំនៅឋាន វិវាទចំនួន ៩៨ករណីបានប៉ះពាល់ដល់ដីស្រែវស្សា វិវាទចំនួន ៤៧ករណីបានប៉ះពាល់ដល់ដីព្រៃសហគមន៍ វិវាទចំនួន ៤៥ករណីបានប៉ះពាល់ដល់ដីព្រៃ វិវាទចំនួន ១៥ករណីបានប៉ះពាល់ដីស្រែប្រាំង វិវាទចំនួន ៥ករណីបានប៉ះពាល់ដល់ព្រៃលិចទឹក។ ប្រភេទដីបឹង ដីចំណីផ្លូវដែក ដីណីប្រឡាយ ដីតំណាម/ព្រៃកប់ខ្មោច/ព្រៃអារក្ស ដីចំណីផ្លូវ មានវិវាទកើតឡើងចំនួន ៣ករណីរៀងខ្លួន។ ចំណែកឯដីកោះ ដីច្រាំងទន្លេ ដីចំណីស្ទឹង ដីត្រពាំងទឹករួម ដីសាលារៀន ដីស្មាក់ការរបស់ភូមិ ដីឡូត៍នេសាទ ដីអូរ ដីព្រៃដែលស្ថិតក្នុងបរិវេណក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដីព្រៃតំបន់ការពារទេសភាពបន្ទាយឆ្មារ មានវិវាទចំនួន១ករណីដូចៗគ្នា។



រូបទី១៥៖ ប្រភេទដីរឯផលប៉ះពាល់ពីវិវាទ

វិវាទដីធ្លីប៉ះពាល់ទំហំដីធំជាងគេក្នុងចំណោម វិវាទទាំង ៣១៤ករណីនៃវិវាទដោះស្រាយបានមួយផ្នែក និងមិនទាន់បានដោះស្រាយ គឺជាវិវាទលើផ្ទៃដី ៧,០៧៦.២០ ហិចតា រវាងប្រជាពលរដ្ឋចំនួន ៦៤៥គ្រួសា ជាប្រភេទដីភូមិ/ដីលំនៅឋាន នៅក្នុងភូមិ ចំនួន៤ភូមិ ដូចជាភូមិសុខសាន្ត ភូមិកោះតូច ភូមិព្រៃកស្វាយ ភូមិដើមថ្កូវ ឃុំកោះរ៉ុង ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ជាមួយក្រុមហ៊ុនរ៉ូយ៉ាល់ក្រុប ករណីនេះរហូតមកដល់ពេលនេះស្ថិតក្នុងដំណើការនៃការដោះស្រាយ។ ចំណែកករណីវិវាទដីធ្លីប៉ះពាល់ទំហំតូចជាងគេ គឺជាវិវាទលើផ្ទៃដីទំហំ ០.១៨ហិចតា ជាដីរបស់សាលារៀន ស្ថិតក្នុងភូមិរលួស ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដីនេះមានវិវាទរវាង ប្រជាពលរដ្ឋ ២,១២៣.០០គ្រួសារ និងលោកគ្រូ អ្នកគ្រូ ជាមួយអតីតនាយកអនុវិទ្យាល័យថ្នាខាន់ ដោយលួចធ្វើប្លង់ដីសាលាស្ងាត់ៗតែ ២នាក់មន្ត្រីសុរិយាដីស្រុកកំពង់ត្របែក រួចកាត់ដីសាលាយកទៅធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន នៅពេលលោកធ្វើជានាយកសាលាអនុវិទ្យាល័យថ្នាខាន់ និងបានធ្វើការសាងសង់

លំនៅឋានលើដីនោះ។ កន្លងមកលោកអភិបាលស្រុកបានចេញលិខិតធ្វើការផ្អាកការសាងសង់ ប៉ុន្តែភាគីខាងចុងបណ្តឹ គឺអតីតនាយកអនុវិទ្យាល័យថ្នាខាន់រូបនេះនៅតែបន្តសាងសង់រហូតដល់រួចរាល់ ហើយករណីនេះនៅតែមិនទាន់មានដំណោះស្រាយនៅឡើយទេ។

៧.២ មូលហេតុនៃទំនាស់ដីធ្លី

នៅក្នុងចំណោមវិវាទ ចំនួន ៣១៤ករណី កំពុងដោះស្រាយនិងរងចាំដំណោះស្រាយ មានវិវាទមានចំនួន ៨៥ករណី បានបង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ការប្រើប្រាស់អំណាច ជាមន្ត្រីរាជការ ទាហាន អាជ្ញាធរ ឧញ្ញា និងជាអ្នកមានទ្រព្យធន រំលោភយកដីរបស់ប្រជាពលរដ្ឋ បានបង្កឲ្យមានវិវាទចំនួន ៤៣ករណី។ ការរំលោភយកដីរដ្ឋធ្វើជាកម្មសិទ្ធិ បានបង្កឲ្យមានវិវាទចំនួន ៣៤ករណី តម្រូវការដីសម្រាប់សាងសង់បន្ទាយទាហាន បានបង្កឲ្យមានវិវាទចំនួន ១៦ករណី តម្រូវការដីសម្រាប់កសិកម្ម បានបង្កឲ្យមានវិវាទចំនួន ១៣ករណី ការរំលោភយកដីព្រៃសហគមន៍ បានបង្កឲ្យមានវិវាទចំនួន ១១ករណី។ តម្រូវការដីសម្រាប់លំនៅឋាន និងបញ្ហាសម្បទានដីសង្គមកិច្ច បានបង្កឲ្យមានវិវាទចំនួន ៧ករណីដូចគ្នា។ ការវិនិយោគរបស់ក្រុមហ៊ុនឯកជន បានបង្កឲ្យមានវិវាទចំនួន ៤ករណី តំបន់អភិវឌ្ឍន៍របស់រដ្ឋ និងការផ្តល់សិទ្ធិរុករករ៉ែ បានបង្កឲ្យមានវិវាទចំនួន ៣ករណីដូចគ្នា។ មានមូលហេតុផ្សេងៗទៀត បង្កឲ្យមានវិវាទចំនួន ៨៣ករណី ដូចជា ការសាងសង់ទំបន់វារីអគ្គិសនី ការលក់ដីរួមរបស់ភូមិ ការស្តារប្រព័ន្ធប្រឡាយទឹកស្អុយ ការជីប្រព័ន្ធធារាសាស្ត្រ ការចេញប័ណ្ណកម្មសិទ្ធិជាន់លើដីរបស់សហគមន៍ ការលក់ទិញដែលមិនគោរពកិច្ចសន្យា ការរំលោភដីបឹង ការរំលោភយកឡូត៍នេសាទ ភាពមិនច្បាស់លាស់នៃព្រំប្រទល់រដ្ឋបាលឃុំ ការយកដីទីស្នាក់ការរបស់ភូមិទៅលក់ ការលក់និងរំលោភយកដីវត្ត ការចុះបញ្ជីជាន់លើដីមានម្ចាស់កាន់កាប់ ការសាងសង់រំលោភលើផ្លូវសាធារណៈ ការអភិវឌ្ឍន៍ផ្លូវរថភ្លើង ដីដែលទិញពីទាហានប្រចាំការនៅក្នុងតំបន់ កិច្ចសន្យាជួល រយៈពេលវែង(៩៩ ឆ្នាំ)ពីរដ្ឋ អាជ្ញាធរខេត្ត និងអាជ្ញាធរឃុំ ជិកយកដីភ្នំ

លក់ ឈ្មួញដីបានចលនាប្រជាពលរដ្ឋឲ្យផ្តិតមេដៃលើលិខិតលក់ទិញ ដោយមិនបានដឹងពីទីតាំងដែលត្រូវលក់ គម្រោងអភិវឌ្ឍសាកលវិទ្យាល័យ ការកាប់ទន្ទ្រានរំលោភដីព្រៃតំនម និងព្រៃកប់ខ្មោចពីមន្ត្រីសាលាស្រុក និងអនុប្រធានភូមិតាមរយៈកិច្ចសន្យាលក់ទិញ ការជួលជុលផ្លូវដែកដោយគំរោងADB ការបិទផ្លូវធ្វើដំណើររបស់ប្រជាពលរដ្ឋ ល។ល។ មានវិវាទចំនួន៧ករណី មិនមានពត៌មានអំពីមូលហេតុបង្កវិវាទ។

ទិន្នន័យនេះ បង្ហាញថាមូលហេតុធំៗ ដែលបង្កឲ្យមានវិវាទដីធ្លី នៅក្នុងប្រទេសកម្ពុជា មានបីសំខាន់ៗគឺ ការផ្តល់ដីសម្បទានដីសេដ្ឋកិច្ចនាពេលកន្លងមក ការប្រើប្រាស់អំណាចជាមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធនិងអំណាចមុខងារជាឧកញ៉ា/អ្នកមាន និងការរំលោភយកដីរដ្ឋធ្វើជាកម្មសិទ្ធិ។



រូបទី១៦៖ មូលហេតុបង្កឲ្យមានវិវាទដីធ្លី

បញ្ហាវិវាទដីធ្លីបង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៦នេះបានធ្លាក់ចុះពីចំនួន ៩៧ករណី មកចំនួន ៨៤ករណី។ នេះដោយសារមានវិវាទចំនួន ១៣ករណី បង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចត្រូវបានដោះស្រាយចប់ពេញលេញទាំងស្រុង ករណីទាំងនោះមាននៅក្នុងខេត្តកំពង់ចាម មាន២ករណី។ វិវាទទីមួយជាវិវាទរវាងប្រជាពលរដ្ឋជាមួយក្រុមហ៊ុន ធី ធី វ៉ាយ(TTY)/ចំការកៅស៊ូមេមត់

វិវាទនេះត្រូវបានបញ្ចប់ដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយសម្រេចប្រគល់ដីទំហំ ៥០ ហិកតា ជូនប្រជាពលរដ្ឋ ៦៣៤ គ្រួសារ ហើយនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកឧត្តម សរ សុវណ្ណ បានចុះជួបប្រជុំប្រកាសតំបន់វិនិច្ឆ័យនិងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងនៅថ្ងៃទី២៣ វិច្ឆិកា ឆ្នាំ២០១៦ ចុះវាស់វែងកំណត់ក្បាលដីក្នុងតំបន់វិនិច្ឆ័យ ដោយចេញបង្គាន់ដៃទុកពិនិត្យលេខក្បាលដីនៅពេលគណៈកម្មការបានបិទផ្សាយរយៈពេល ៣០ ថ្ងៃ (ពិនិត្យ និងបើកផ្លូវឲ្យតវ៉ា)។ វិវាទមួយករណីទៀតគឺវិវាទរវាងក្រុមហ៊ុនអាហ្គោស្តារ ជាមួយប្រជាពលរដ្ឋ១៦គ្រួសារ លើផ្ទៃដីទំហំ ៣២ ហិចតា បច្ចុប្បន្នប្រជាពលរដ្ឋបានកំពុងកាន់កាប់ និងមិនមានការជំទាស់ពីភាគីក្រុមហ៊ុនទៀតឡើយ។

នៅក្នុងខេត្តមណ្ឌលគិរី មានវិវាទចំនួន ២ករណី បង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចត្រូវបានដោះស្រាយចប់ពេញលេញទាំងស្រុង ករណីទីមួយវិវាទរវាប្រជាពលរដ្ឋ ៨៥គ្រួសារ ជាមួយក្រុមហ៊ុន សុវណ្ណរាជស៊ី វិវាទនេះត្រូវបានដោះស្រាយដោយផ្នែកនៅក្នុងឆ្នាំចុងឆ្នាំ២០១៥ ដោយភាគីក្រុមហ៊ុនផ្តល់សំណងសរុបចំនួន ២ម៉ឺនដុល្លាសហរដ្ឋអាមេរិចដល់ប្រជាពលរដ្ឋរងផលប៉ះពាល់ ប៉ុន្តែក្នុងនោះមានប្រជាពលរដ្ឋ ចំនួន៦គ្រួសារមិនព្រមទទួលសំណង និងនៅតែបន្តប្តឹង រហូតដល់ឆ្នាំ២០១៦ ប្រជាពលរដ្ឋ ៣គ្រួសារក្នុងចំណោមប្រជាពលរដ្ឋទាំង ៦គ្រួសារនោះបានព្រមទទួលយកសំណង ហើយក្រុមហ៊ុននៅតែបន្តរងចាំប្រជាពលរដ្ឋនៅសេសសល់ទៅទទួលយកប្រាក់សំណង។ វិវាទមួយករណីទៀត ជាវិវាទរវាងក្រុមហ៊ុនខ្មែរអង្គរ ជាមួយប្រជាពលរដ្ឋចំនួន ២៥៦គ្រួសារ លើផ្ទៃដីទំហំ ៣០០ហិកតា ករណីនេះនៅក្នុងឆ្នាំ ២០១២ ត្រូវបានដោះស្រាយបានមួយផ្នែកតាមការអនុវត្តបទបញ្ជា ០១ ប៉ុន្តែមានការជំទាស់ពីភាគីក្រុមហ៊ុន រហូតមកដល់ឆ្នាំ២០១៦ ក្រុមការងារខេត្តចុះវាស់វាងដីដាំដុះជាក់ស្តែង បច្ចុប្បន្នបានវាស់វែងនិងប័ណ្ណកម្មសិទ្ធិឲ្យប្រជាពលរដ្ឋអស់ហើយ។

ចំណែកឯខេត្តកោះកុងមានចំនួន ២ករណីដូចគ្នា បង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចត្រូវបានដោះស្រាយចប់ពេញលេញទាំងស្រុង ករណីទីមួយជា

វិវាទរវាងក្រុមហ៊ុន លី យ៉ុងផាត់ (LYP) ជាមួយប្រជាពលរដ្ឋ ១៦០គ្រួសារ វិវាទនេះបានដោះស្រាយដោយផ្នែកតាំងពីឆ្នាំ២០១១ ដោយក្រុមហ៊ុនផ្តល់ជាសំណងទៅតាមប្រភេទដី រហូតមកដល់បច្ចុប្បន្ននៅមានប្រជាពលរដ្ឋតែ៣គ្រួសារប៉ុណ្ណោះនៅមិនទាន់ព្រមទទួលយកសំណង។ ករណីមួយទៀតជាវិវាទរវាងក្រុមហ៊ុន Pineapple/Cost Development Group Co.,Ltd ជាមួយប្រជាពលរដ្ឋ ១៦គ្រួសារ លើផ្ទៃដីទំហំ ១៣០ហិកតា វិវាទនេះចាប់ផ្តើមមានដំណោះស្រាយតាំងពីឆ្នាំ ២០១២ មកម្ល៉ះ ដោយភាគីខាងក្រុមហ៊ុនផ្តល់ជាសំណង ៣,៥០០.០០ ដុល្លាសហរដ្ឋអាមេរិច ក្នុងផ្ទៃដីទំហំមួយហិកតា រហូតមកដល់ឆ្នាំ២០១៦នេះ នៅសល់តែមួយគ្រួសារតែប៉ុណ្ណោះដែលមិនទាន់ព្រមទទួលយកសំណង ដោយសារដីរបស់គាត់មានដំណាំច្រើនមិនសមនឹងតម្លៃដែលក្រុមហ៊ុនផ្តល់ឲ្យ។

ខេត្តកំពង់ធំ មានវិវាទចំនួន ១ករណី បង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចត្រូវបានដោះស្រាយចប់ពេញលេញទាំងស្រុង នោះគឺជាវិវាទរវាងក្រុមហ៊ុនតាន់ បៀន(វៀតណាម) ជាមួយប្រជាពលរដ្ឋ ១៦គ្រួសារ លើផ្ទៃដីទំហំ ៣៩ហិកតា ករណីនេះសាលាខេត្តកំពង់ធំបានសំរេចចេញលិខិតជូនដំណឹង ស ជ ណ លេខ ១០៩ ចុះថ្ងៃទី ០៦ ០៨ ២០០៧ តម្រូវឲ្យប្រជាពលរដ្ឋនៅតំបន់បន្ទាយរវៀង ស្ថិតនៅក្នុងភូមិថ្មសំលៀង ឲ្យទៅរស់នៅតំបន់ ត្រពាំងឫស្សី ស្ថិតក្នុងភូមិថ្មសំលៀង ឃុំក្រយា ស្រុកសន្ទុកដដែល តែប្រជាពលរដ្ឋមិនព្រមទៅនៅ ក៏កើតមានទំនាស់។ ករណីនេះនៅក្នុងឆ្នាំ២០០៩ ដោយប្រជាពលរដ្ឋមិនព្រមចេញអាជ្ញាធរខេត្ត ស្រុក បានបង្ខំប្រើកម្លាំងយោធា ធ្វើការបណ្តេញប្រជាពលរដ្ឋឲ្យចេញពីតំនប់នោះជាបណ្តើរៗទៅនៅដីថ្មី ដោយផ្តល់ដីកសិកម្ម និងដីលំនៅឋាន រហូតមកដល់ឆ្នាំ២០១៦នេះប្រជាពលរដ្ឋបានព្រមព្រៀងទទួលយកដីទាំងនោះនិងមិនមានទំនាស់អ្វីជាមួយភាគីក្រុមហ៊ុនទៀតទេ ហើយបានចុះបញ្ជីដីរួចរាល់អស់ហើយ។

ខេត្តកំពត មានវិវាទចំនួន ១ករណី បង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចត្រូវបានដោះស្រាយចប់ពេញលេញទាំងស្រុង គឺវិវាទរវាងក្រុមហ៊ុន វ៉ាន់ វណ្ណា (ខេម

បូឌា) គ្រួបខូអិលធីឌី ជាមួយប្រជាពលរដ្ឋ ១២គ្រួសារ លើផ្ទៃដីទំហំ ២ហិកតា ករណីនេះដំណើការដោះស្រាយដោយតុលាការសាលាឧទ្ធរណ៍ និងភាគីក្រុមហ៊ុនយល់ព្រមប្រគល់ដីនេះទៅឲ្យប្រជាពលរដ្ឋដើមបណ្តឹងទាំង ១២គ្រួសារនោះវិញ។

ខេត្តព្រះវិហារ មានវិវាទចំនួន ១ករណី បង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចត្រូវបានដោះស្រាយចប់ពេញលេញទាំងស្រុង គឺវិវាទរវាងក្រុមហ៊ុនEminent Elite (cambodia Co., Ltf) ជាមួយប្រជាពលរដ្ឋ ៩៨គ្រួសារ លើផ្ទៃដីទំហំ ៤៩១.៣៦ ហិកតា ករណីនេះត្រូវបានដោះស្រាយតាមរយៈការតវ៉ាពីប្រជាពលរដ្ឋរងផលប៉ះពាល់ដោយមានកិច្ចអន្តរាគមន៍ពីសមាគមន៍អាដហុកទៅសាលាខេត្ត និងមន្ត្រីជំនាញសុរិយោដីខេត្តជាលទ្ធផលប្រជាពលរដ្ឋរងផលប៉ះពាល់បានទទួលបានដីទំនាស់នោះមកវិញ ចំណែកភាគីក្រុមហ៊ុនក៏បានក្ស័យធនផងដែរ។

ចំណែកឯវិវាទបង្ករឡើងដោយក្រុមហ៊ុសម្បទានដីសេដ្ឋកិច្ច ចំនួន ៨៤ករណី ដែលកំពុងរចាំដំណោះស្រាយ ក្នុងនោះខេត្តរតនគិរី មានចំនួន១៤ករណី ខេត្តមណ្ឌលគិរី និងខេត្តកំពង់ស្ពឺ មានចំនួន១១ករណី ខេត្តពោធិ៍សាត មានចំនួន៩ករណី ខេត្តក្រចេះ មានចំនួន៧ករណី។ ខេត្តស្វាយរៀង និងខេត្តព្រះវិហារ មានចំនួន៦ករណី ខេត្តកោះកុង មានចំនួន៥ករណី ខេត្តព្រះសីហនុ មានចំនួន៣ករណី។ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ មានចំនួន២ករណីដូចគ្នា។ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពត ខេត្តឧត្តរមានជ័យ ខេត្តស្ទឹងត្រែង និងខេត្តត្បូងឃ្មុំ មានចំនួន១ករណីដូចគ្នា។ វិវាទនេះប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ១៥,៩៨៥.០០ គ្រួសារ លើផ្ទៃដីប្រមាណជា ១០៦,១៣១.២០ ហិកតា។



រូបទី១៧៖ វិវាទបង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចតាមបណ្តាខេត្ត

៨. ឯកសារប្រើប្រាស់ដោយភាគីខិទាទក្នុងការទទួលបានដី

នៅក្នុងការទាមទារដីដោយគូរភាគីវិវាទ មានឯកសារជាច្រើនប្រើប្រាស់ជាសំអាងក្នុងការបញ្ជាក់ពីភាពជាម្ចាស់ទៅលើដីវិវាទ ឯកសារទាំងនោះមានទាំងឯកសារផ្លូវច្បាប់ និងស្ថានភាពកាន់កាប់ជាក់ស្តែង។ នៅក្នុងចំណោមវិវាទទាំង ៣១៤ករណី មានវិវាទចំនួន ៨៨ករណី សំអាងលើកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច ៥២ករណី សំអាងការកាន់កាប់/ការរស់នៅនិងអាស្រ័យផលជាក់ស្តែង ៤៤ករណី សំអាងលើលិខិតទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន ៣៧ករណី សំអាងលើកិច្ចសន្យាលក់-ទិញ ៣៤ករណី សំអាងលើការតាំងលំនៅឋានមិនរៀបរយ ២៥ករណី សំអាងលើសិទ្ធិជាប្រពៃណី ១៩ករណី សំអាងលើប័ណ្ណកម្មសិទ្ធិ (Land Title,LMAP certificate) ១២ករណី សំអាងលើកិច្ចព្រមព្រៀងសហគមបន៍/បទបញ្ជាផ្ទៃក្នុងសហគមន៍/ផែទីសហគមន៍/លិខិតកំណត់ព្រំប្រទល់សហគមន៍ ១១ករណី សំអាងលើអនុក្រឹត្រ/ស.ជ.ណ/សេចក្តីជូនដំណឹង/ប្រកាស ៨ករណី សំអាងលើពាក្យសុំកាន់កាប់ប្រើប្រាស់ដី ៧ករណី សំអាងលើប័ណ្ណកម្មសិទ្ធិ/ប័ណ្ណសម្គាល់ការកាន់កាប់/ប្រើប្រាស់ដីធ្លី ៦ករណី សំអាងលើកិច្ចសន្យាផ្តល់សម្បទានដីសង្គមកិច្ច។ ការសំអាងលើប័ណ្ណស្លាបមាន់និងការសំអាងលើបង្កាន់ដៃឬចុងសន្លឹក មានចំនួន ៥ករណីដូចគ្នា។ ការសំអាងលើរបបដីសមាហរណកម្មជូនយោធិនពិការនិងខ្មែរក្រហម និងការសំអាងលើឯកសារបញ្ជាក់ថាជាដីរដ្ឋ មានចំនួន ៤ករណីដូចៗគ្នា ហើយវិវាទចំនួន៣ករណី សំអាងលើកិច្ចសន្យារ៉ុករកស៊ែ។ ការសំអាងលើការបែងចែកដីក្នុងឆ្នាំ១៩៨៩ ការសំអាងលើប័ណ្ណស្លាបមាន់ និងសំអាងជាដីរួមរបស់ភូមិ មានចំនួន ២ករណីដូចគ្នា និងមាននវិវាទ ១១ករណីបានប្រើប្រាស់និងសំអាងលើឯកសារផ្សេងៗដូចជា ឯកសារដែលខាងសុរិយោដីវាស់វែងការទទួលស្គាល់ពីក្រសួងមហាផ្ទៃនូវនិតិបុគ្គលស្របច្បាប់ជាសហគមន៍ជនជាតិដើមភាគតិច ប័ណ្ណបោះឆ្នោត/សៀវភៅគ្រួសារ/អត្តសញ្ញាណប័ន ដីវត្ត/ដីផ្លូវសាធារណៈ/ដីរួមភូមិ សំអាងបទបញ្ជាពីថ្នាក់លើ លិខិតកាន់កាប់បណ្តោះ

អាសន្ន ដីកេរ្តិ៍សម្រាប់បញ្ចុះសព ប័ណ្ណកម្មសិទ្ធិក្នុងឆ្នាំ១៩៩៧ និងដីបន្ទាយទាហាន។



រូបទី១៨៖ ឯកសារគូរភាគីវិវាទប្រើប្រាស់ជាសំអាងក្នុងការទាមទារដីវិវាទ

វិវាទចំនួន ៥២ករណី បានសំអាងលើការរស់នៅ/កាន់កាប់/ប្រើប្រាស់និងការអាស្រ័យផលជាក់ស្តែង ក្នុងការទាមទារឬជាសំអាងអំពីភាពស្របច្បាប់របស់ខ្លួនកើតមាននៅក្នុងខេត្តចំនួន ១៣ខេត្ត និងរាជធានី។ ក្នុងនោះខេត្តបន្ទាយមានជ័យមានវិវាទ ចំនួន១៣ករណី ជាចំនួនច្រើនជាងគេ បន្ទាប់គឺខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ មានចំនួន ១០ករណីដូចគ្នា។ ខេត្តត្បូងឃ្មុំនិងរាជធានីភ្នំពេញ ចំនួន៣ករណីដូចគ្នា។ ខេត្តព្រៃវែង ខេត្តកោះកុង ខេត្តមណ្ឌលគិរី ខេត្តសៀមរាប ចំនួន២ករណីដូចគ្នា។ ខេត្តស្វាយរៀង ខេត្តកណ្តាល ខេត្តព្រះវិហារ ខេត្តពោធិសាត់ ខេត្តរតនគិរីចំនួន ១ករណីដូចៗគ្នា។

លិខិតទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋានភូមិ/ឃុំ/ស្រុក ត្រូវបានគូរភាគីវិវាទចាត់ទុកថាជាឯកសារមួយប្រភេទដែលជួយដល់ពួកគេក្នុងការសំអាងភាពជាម្ចាស់លើដីវិវាទ បើទោះជាឯកសារនេះពេលខ្លះអាចត្រូវបានបង្កើតឡើងក្នុងលក្ខខ័ណ្ឌមួយដែលមិនត្រឹមត្រូវឬមានភាពមិនប្រក្រតីក្តី។ គូរភាគីវិវាទក្នុងករណីចំនួន ៤៣ករណី ក្នុងចំណោមវិវាទទាំង៣១៤ករណី បានប្រើប្រាស់ឯកសារនេះក្នុងការទាមទារ

ឬសំអាងភាពជាម្ចាស់ដីវិវាទ ក្នុងនោះខេត្តព្រះសីហនុ មានចំនួន ៩ករណី ខេត្តកោះកុង និងខេត្តពោធិ៍សាត់ មានចំនួន ៧ករណី។ ខេត្តបន្ទាយមានជ័យ និងខេត្តរតនគិរី មានចំនួន ៣ករណី ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តក្រចេះ និងរាជធានីភ្នំពេញមានចំនួន ២ករណីដូចគ្នា។ ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងខេត្តត្បូងឃ្មុំ មានចំនួន ១ករណីដូចៗគ្នា។

កិច្ចសន្យាលក់-ទិញ ដែលជាទូរទៅតែងឃើញមានការចុះហត្ថាលេខាពីអាជ្ញាធរមូលដ្ឋាន និងពេលខ្លះមិនមាន ក៏ត្រូវបានគូរភាគីវិវាទយកមកប្រើប្រាស់ជាសំអាងក្នុងការទាមទារដីវិវាទផងដែរ។ ជាក់ស្តែង មានវិវាទ ៣៧ករណី ក្នុងចំណោមវិវាទចំនួន ៣១៤រកណី កំពុងប្រើប្រាស់ឯកសារនេះ ក្នុងនោះខេត្តបន្ទាយមានជ័យ មានចំនួន ៩ករណី ខេត្តកំពង់ស្ពឺ និងរាជធានីភ្នំពេញ មានចំនួន ៥ករណីដូចគ្នា។ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តរតនគិរី និងខេត្តព្រះសីហនុ មានចំនួន ៣ករណីដូចគ្នា។ ខេត្តកោះកុងមាន ២ករណី និងខេត្តមណ្ឌលគិរី មាន១ករណី។

ការសំអាងលើការតាំងលំនៅឋានមិនរៀបរយឬបណ្តោះអាសន្នរបស់ប្រជាពលរដ្ឋនៅលើដីទំនេររបស់រដ្ឋ មួយចំនួនក៏តែងតែបង្កឲ្យមានវិវាទផងដែរ ហើយនៅពេលមានវិវាទពួកគេសំអាងលើរយៈពេលដែលពួកគេបានមករស់នៅមុនពេលកើតមានវិវាទ។ មានវិវាទចំនួន ៣៤ករណី ក្នុងចំណោម ៣១៤ករណី ការសំអាងលើការតាំងលំនៅឋានមិនរៀបរយឬបណ្តោះអាសន្នក្នុងការតទល់ទៅនឹងគូរភាគីវិវាទ ក្នុងនោះខេត្តបន្ទាយមានជ័យ មាន៦ករណី ខេត្តព្រះវិហារ មាន៥ករណី ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ មានន៤ករណី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង មាន៣ករណី ខេត្តកោះកុង ខេត្តមណ្ឌលគិរី និងរាជធានីភ្នំពេញ មាន២ករណី ខេត្តកណ្តាល ខេត្តក្រចេះ និងខេត្តពោធិ៍សាត់ មាន១ករណី។

សិទ្ធិជាប្រពៃណី ជាទូរទៅសំដៅដល់សិទ្ធិជាប្រពៃណីរបស់ជនជាតិដើមភាគតិចទៅលើការប្រើប្រាស់ដី អាចជាដីស្រែឬដីចំការពរនេចរ/ចំការរំលុំ ដោយមិន

មានលិខិតស្នាមបញ្ជាក់ពីឈ្មោះម្ចាស់ឬទីតាំងដីនោះឡើយ គឺគ្រាន់តែមានការដឹងឮពីប្រជាពលរដ្ឋក្បែរខាង ឬ ក្នុងភូមិ ឬ អាជ្ញាធរតែប៉ុណ្ណោះ។ វិវាទប្រភេទនេះ មានវិវាទរវាងប្រជាពលរដ្ឋជាជនជាតិដើមភាគតិច ជាមួយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដោយមានចំនួន ១៨ករណី ក្រុមហ៊ុនឯកជន មាន២ករណី ឈ្មួញខិលខូច មាន២ករណី និងអ្នកមានអំណាចនិងទ្រព្យធន មាន២ករណី។ វិវាទទាំងនោះកើតនៅក្នុងខេត្តរតនគិរី មាន១៤ករណី ខេត្តមណ្ឌលគិរី មាន៨ករណី ខេត្តកំពង់ស្ពឺ ខេត្តក្រចេះ និងខេត្តព្រះសីហនុ មាន១ករណីដូចគ្នា។

ដីដែលមានប័ណ្ណកម្មសិទ្ធិ (Land Title,LMAP certificate) ក៏នៅតែជៀសមិនផុតពីវិវាទដូចដីមិនបានចុះបញ្ជីដែរ។ ជាក់ស្តែងមានវិវាទចំនួន ១៩ករណី ក្នុងចំណោមវិវាទ ៣១៤ករណី គួរភាគីវិវាទមានប័ណ្ណកម្មសិទ្ធិ (Land Title,LMAP certificate) ក្នុងការសំអាងលើភាពជាម្ចាស់ស្របច្បាប់របស់ខ្លួន ក្នុងនោះខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ មាន៤ករណី ខេត្តបន្ទាយមានជ័យ និងខេត្តកោះកុង មាន៣ករណី រាជធានីភ្នំពេញ មាន២ករណី។ ខេត្តមណ្ឌលគិរី ខេត្តពោធិ៍សាត់ និងខេត្តរតនគិរី មាន១ករណីដូចគ្នា។

ដីព្រៃ ដីព្រៃលិចទឹក ដៃស្ទឹង ឬទន្លេ មួយចំនួន ត្រូវបានផ្តួចផ្តើមនិងចងក្រងជាសហគមន៍ សម្រាប់ការគ្រប់គ្រង និងប្រើប្រាស់ឲ្យមានចេរភាពនិងប្រសិទ្ធភាពនូវធនធានធម្មជាតិ ដូចជាព្រៃឈើ សត្វព្រៃ មច្ឆាជាតិ និងប្រភពទឹកជាដើម ហើយការថែរក្សាធនធានទាំងនេះគឺដើម្បីធានានិងគាំពារដល់ជីវភាពរស់របស់ប្រជាសហគមន៍។ តាមរយៈនិតិវិធីនៃការរៀបចំចងក្រងបង្កើតសហគមន៍ព្រៃឈើ សហគមន៍ព្រៃការពារ សហគមន៍នេសាទ សហគមន៍ទាំងនោះរំពឹងថាក្រោយទទួលបានកិច្ចព្រមព្រៀង សហគមន៍ពីស្ថាប័នមានសមត្ថកិច្ចនឹងអាចមានសុវត្ថិភាពនៃការគ្រប់គ្រង។ ផ្ទុយមកវិញយើងឃើញមានវិវាទ ចំនួន១២ករណី បានប្រើប្រាស់កិច្ចព្រមព្រៀងសហគមន៍/បទបញ្ជាផ្ទៃក្នុងសហគមន៍/ផែទីសហគមន៍/លិខិតកំណត់ព្រំប្រទល់សហគមន៍ ជាសំអាងក្នុងការទាមទារដីពីគួរភាគីវិវាទ។ វិវាទប្រភេទនេះកើត

មាននៅក្នុងខេត្តឧត្តរមានជ័យ មាន៥ករណី ខេត្តត្បូងឃ្មុំ មាន៣ករណី ខេត្តកំពង់ឆ្នាំង មាន២ករណី។ ចំណែកខេត្តកំពត ខេត្តពោធិ៍សាត់ និងខេត្តស្វាយរៀង មាន១ករណីដូចគ្នា។ ជាឧទាហរណ៍ មានសហគមន៍ព្រៃឈើចំនួន ៥សហគមន៍ក្នុងចំណោមសហគមន៍ព្រៃឈើ ១៣សហគមន៍ដែលទទួលបានកិច្ចព្រមព្រៀងសហគមន៍ពីរដ្ឋបាលព្រៃឈើក្នុងអំឡុងឆ្នាំ ២០០៨ និងឆ្នាំ២០០៩ កំពុងកើតមានវិវាទដីធ្លីជាមួយទាហាន ក៏ដូចជាក្រុមគ្រួសារទាហានដែលកំពុងរៀបចំបន្ទាយនៅក្នុងខេត្តនេះ។ សហគមន៍ព្រៃឈើទាំងនោះមានដូចជា សហគមន៍ទាំងនោះមានដូចជា សហគមន៍ព្រៃឈើអណ្តូងបរ សហគមន៍ព្រៃឈើដុងបេង សហគមន៍ព្រៃឈើភ្នំដងរ៉ែ កសំរ៉ែកព្រៃស្រស់ និងសហគមន៍រតនៈវុក្ខា។



រូបទី១៩៖ ឯកសារគួរភាគីវិវាទសំអាងក្នុងការទាមទារដីវិវាទតាមបណ្តាខេត្ត

៩. ការកាន់កាប់បច្ចុប្បន្នលើដីមានវិវាទ

ដីវិវាទទាំង ៣១៤ករណី មានស្ថានភាពនៃការកាន់កាប់ ឬការគ្រប់គ្រង ឬប្រើប្រាស់ដី ខណៈកំពុងទំនាស់មានលក្ខណៈខុសគ្នា ពីករណីមួយទៅករណីមួយ។

១០១ករណីស្មើរនឹង៣៥.០៣ភាគរយ កំពង់ប្រើប្រាស់ដោយភាគីចុងបណ្តឹង វិវាទដីធ្លី ចំនួន ៨៤ករណីស្មើរនឹង២៦.៧៥ភាគរយនៃករណីដែលកំពុងកើតមាននិងរងចាំការដោះស្រាយ កំពុងប្រើប្រាស់ដោយដើមបណ្តឹង វិវាទចំនួន ៥៣ករណីស្មើរ១៦.៨៧ ភាគរយ កំពុងប្រើប្រាស់ដោយភាគីទាំងសងខាង និងវិវាទចំនួន ៦៧ករណីស្មើរនឹង ២១.៣៣ភាគរយ មិនបានដឹងពីស្ថានភាពនៃការប្រើប្រាស់។

ស្ថានភាពប្រើប្រាស់លើដីវិវាទ	# វិវាទ
កំពុងប្រើប្រាស់ដោយដើមបណ្តឹង	៨៤
កំពង់ប្រើប្រាស់ដោយភាគីចុងបណ្តឹង	១០១
កំពុងប្រើប្រាស់ដោយភាគីទាំងសងខាង	៥៣
មិនបានដឹងពីស្ថានភាពនៃការប្រើប្រាស់	៧៦
សរុប	៣១៤

តារាងទី ៣: ស្ថានភាពនៃការកាន់កាប់ដីធ្លីនៅលើវិវាទដីធ្លី

ជាមួយគ្នានេះ វិវាទចំនួន ៨៤ករណី បង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច កំពុងបន្ត និងរងចាំដំណោះស្រាយ ក្នុងនោះវិវាទ៨០ករណី ដែលមានភាគីខាងក្រុមហ៊ុនជាចុងបណ្តឹង និង៤ករណី ភាគីក្រុមហ៊ុនជាដើមបណ្តឹង។ នៅក្នុងវិវាទ ៨០ ករណី មានភាគីក្រុមហ៊ុនជាចុងបណ្តឹងនោះ ភាគីក្រុមហ៊ុនបានកំពុងប្រើប្រាស់ដីវិវាទចំនួន២៤ករណី វិវាទ២៣ករណី ដីវិវាទកំពុងប្រើប្រាស់ដោយដើមបណ្តឹងជាប្រជាពលរដ្ឋ វិវាទ២៥ករណី កំពុងប្រើប្រាស់ដោយគូរភាគីវិវាទ និងវិវាទ ៩ករណី មិនមានពត៌មានអំពីស្ថានភាពនៃការប្រើប្រាស់លើដីវិវាទទេ។ ចំណែកឯ វិវាទ ៤ ករណីដែលភាគីក្រុមហ៊ុនជាដើមបណ្តឹងនោះ មានវិវាទ ២ករណី ដីវិវាទកំពុងប្រើប្រាស់ដោយចុងជាប្រជាពលរដ្ឋ និង២ករណី ដីវិវាទកំពុងប្រើប្រាស់ដោយភាគីក្រុមហ៊ុន។

នៅក្នុងវិវាទទាំង ៣១៤ករណីនេះ យើងសង្កេតឃើញកន្លងមកគូរភាគីវិវាទ បានព្យាយាមប្រើគ្រប់រូបភាពដើម្បីការពារ និងទាមទារនូវដីវិវាទ។ តាមរយៈការ

ការពារ និងការទាមទារនេះ បានបង្កឲ្យមានជាការគំរាមកំហែង ការប្រើប្រាស់អំពើរហឹង្សា ការចាប់ឃុំខ្លួន/ឃាត់ខ្លួន។ មានវិវាទ ចំនួន ៥៨ករណី មានការប្រើប្រាស់នូវការគំរាមកំហែង វិវាទ ចំនួន៤៧ករណី មានការប្រើប្រាស់អំពើហឹង្សា វិវាទ ចំនួន ៤១ករណី កន្លងមកធ្លាប់មាន ការចាប់ឃុំខ្លួនគូរភាគីវិវាទ។

វិវាទចំនួន ៤១ករណី កន្លងមកធ្លាប់មានការចាប់ឃុំខ្លួនគូរភាគីវិវាទ ក្នុងនោះមាន ចំនួន ១៧ករណី ជាវិវាទបង្កដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ៣ករណី ដោយសារតម្រូវការដីសម្រាប់លំនៅឋាន ២ករណី ដោយសារការផ្តល់ដីសម្បទានសង្គមកិច្ច ២ករណីទៀតដោយសារតម្រូវការដីសម្រាប់កសិកម្ម វិវាទ ចំនួន ១ករណី បង្កដោយការអភិវឌ្ឍន៍របស់រដ្ឋ និងវិវាទ ចំនួន ១៧ករណីទៀតដោយសារមូលហេតុផ្សេងៗ។ ជាក់ស្តែង ករណីលេខ ២៨១៧ ជាវិវាទរវាង ប្រជាពលរដ្ឋ ២៧ គ្រួសារ ជាប្រជាពលរដ្ឋចំណូលស្រុកមកប្រកបរបរជីកត្បូង លើផ្ទៃដី ៥០ហិកតា ស្ថិតនៅភូមិរ៉ៃ ឃុំកិះចុង ស្រុកបរកែវ ខេត្តរតនគិរី។ វិវាទនេះកើតឡើង ដោយសារប្រជាពលរដ្ឋ ១៩១គ្រួសារដែលប្រកបរបរជីកត្បូង តាំងពីឆ្នាំ ២០០៩ រហូតដល់ឆ្នាំ ២០១២ លើដីដែលខាងភូមិរ៉ៃយ បានលក់ទៅឲ្យភាគីដើមបណ្តឹង កំពុងព្យាយាមបង្កើតជាភូមិថ្មី (ភូមិរ៉ៃយទី២) តាមរយៈការស្នើរសុំគោលការណ៍ទៅឃុំ ស្រុក។ ក្រោយមក ភាគីដើមបណ្តឹង (លោក ជាតិ) បានដាក់ពាក្យបណ្តឹងទៅតុលាការ ដោយចោទ លោក សូត្រ សឿន ជាតំណាងប្រជាពលរដ្ឋ ១៩១គ្រួសារពីបទរំលោភយកមដីកម្មសិទ្ធឯកជន។ ករណីនេះមានប្រជាពលរដ្ឋ ៣នាក់ ជាប់ឃុំខ្លួននៅសាលាដំបូងខេត្តរតនគិរី កាលពីថ្ងៃទី ២ ធ្នូ ឆ្នាំ២០១៥ ហើយត្រូវអ្នកភូមិប្រហែល ១០០នាក់ ចូលរួមធ្វើបាតុកម្មមុខតុលាការ ហើយបានវាយកំទេចរបងតុលាការផងដែរ។

១០. ទិន្នន័យដីធ្លីដែលបង្កផលប៉ះពាល់លើជនជាតិដើមភាគតិច

ក្នុងចំណោមវិវាទ ៣១៤ករណី មានវិវាទ ៤៤ករណី ស្មើរនឹង១៣.៦៩ភាគរយ

កំពុងបន្តប៉ះពាល់ដល់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិច នៅក្នុងខេត្តចំនួន៧ មានដូចជា ខេត្តរតនគិរី មាន២០ករណី ខេត្តមណ្ឌលគិរី មាន១១ករណី ខេត្តកំពង់ស្ពឺ មាន៥ករណី ខេត្តព្រះវិហារ មាន៤ករណី ខេត្តក្រចេះ មាន២ករណី ខេត្តកោះកុង[13] និងខេត្តពោធិ៍សាត់ មាន១ករណីដូចគ្នា។ វិវាទទាំងនេះ ប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ៩,៤០៦.០០ គ្រួសារ លើផ្ទៃដី ៥៥,៣២៤.៥១ ហិកតា ក្នុងនោះផ្ទៃដីវិវាទធំបំផុតមានទំហំ ៩,០០០.០០ ហិកតា ជាវិវាទរវាងប្រជាពលរដ្ឋ ២៧៣គ្រួសារ[14] ជាមួយក្រុមហ៊ុន CT Martនិងក្រុមហ៊ុន Phnom Penh Sugar(ករណីលេខ២៦៩០) ជាប្រភេទដីចម្រុះប្រើប្រាស់សម្រាប់លំនៅឋាន ដីស្រែ និងដីចំការ ស្ថិតក្នុងឃុំចំនួន៣ គឺឃុំយាងអង្គ ឃុំមុំប្រាំបី និងឃុំអមលាំង។ វិវាទនេះកើតតាំងពីឆ្នាំ ២០១០ ដោយពីដំបូងវិវាទនេះជាវិវាទជាមួយក្រុមហ៊ុន CT Mart ដែលបានទទួលសិទ្ធិវិនិយោគសម្បទានដីសេដ្ឋកិច្ចពីរដ្ឋាភិបាល លុះក្រោយមកក្រុមហ៊ុននេះបានផ្ទេរសិទ្ធិទៅឲ្យក្រុមហ៊ុន Phnom Penh Sugar ករណីនេះដោះស្រាយបានមួយផ្នែកហើយ។ វិវាទផ្ទៃដីតូចបំផុតមានទំហំ ១០ហិកតា ជារវាងប្រជាពលរដ្ឋ ២០គ្រួសារ ជាមួយក្រុមហ៊ុន ហ៊ីង អាញលំផាត់លើផ្ទៃដីទំហំ ១០ហិតា ស្ថិតក្នុងភូមិ៣ ឃុំស្រែអង្រ្កែង ស្រុក កូនមុំ ខេត្តរតនគិរី វិវាទនេះកើតឡើងនៅក្នុងឆ្នាំ ២០១៤ ដោយភាគីខាងក្រុមហ៊ុនបានឈូសឆាយដីចំការរបស់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិច ហើយរហូតមកដល់បច្ចុប្បន្ននេះនៅតែមិនទាន់មានដំណោះស្រាយនៅឡើយទេ។

[13] *ប្រជាពលរដ្ឋដែលមានវិវាទក្នុងខេត្តកោះដែលសំអាងថាពួកគាត់ជាជនជាតិដើមភាគតិចនេះពុំមានឯកសារផ្លូវការណាសំគាល់នោះទេ គឺគាត់ធ្វើការសំអាងផ្ទាល់មាត់*

[14] *សម្រាប់ប្រជាពលរដ្ឋ ២៧៣គ្រួសារនេះមិនមានឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ពួកគាត់ថាជាប្រជាជនជនជាតិដើមភាគតិចទេ គឺប្រជាពលរដ្ឋក្នុងចំណោម២៧៣គ្រួសារ ប្រើសំអាងផ្ទាល់មាត់*



រូបទី២០៖ ចំនួនវិវាទប៉ះពាល់ដល់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិច និងចំនួនគ្រួសារដែលរងផលប៉ះពាល់

ដោយឡែក មានវិវាទ៣៤ករណី ក្នុងចំណោមវិវាទ ៥៥ករណីនៃវិវាទដែលប៉ះពាល់ដល់ប្រជាពលរដ្ឋជនជាតិដើមភាគតិច គឺបង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច កើតមាននៅក្នុងខេត្តចំនួន ៦ មានដូចជា ខេត្តរតនគិរី មាន១៣ករណី ខេត្តមណ្ឌលគិរី មាន៩ករណី ខេត្តកំពង់ស្ពឺ មាន៥ករណី ខេត្តព្រះវិហារ មាន៣ករណី ខេត្តក្រចេះ មាន២ករណី ខេត្តពោធិ៍សាត់ និងខេត្តកោះកុង មាន១ករណី។

ខេត្តរតនគិរី មានករណីវិវាទដីធ្លីប៉ះពាល់ដល់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិច ដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចច្រើនជាងគេ មានចំនួន ១៣ករណី ស្មើនឹង ២,០៦៥.០០ គ្រួសារ។ ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចទាំងនោះមានដូចជា ក្រុមហ៊ុនជាំងលី ក្រុមហ៊ុនហោងប្រាឌ័រ ក្រុមហ៊ុនហ្វីលី ក្រុមហ៊ុនហ៊ាងអាញអូរយ៉ាដាវ ក្រុមហ៊ុន

ជីងសុងរី ក្រុមហ៊ុនAgrico., Coltd(បច្ចុប្បន្នលក់ឲ្យហ៊ុងអាញលំជាត់) ក្រុមហ៊ុនម៉ែន សារ៉ុន(ហៅក្រុមហ៊ុនន ៧២) ក្រុមហ៊ុន C R D (បច្ចុប្បន្ន ក្រុមហ៊ុនហ៊ុងអាញ) ក្រុមហ៊ុនអេវឡេវប៊ីអឹមចញស្ពុក ក្រុមហ៊ុនហ៊ុងអាញលំជាត់ ក្រុមហ៊ុន៧កមការជារី។

ខេត្តមណ្ឌលគិរី មានករណីវិវាទដីធ្លីប៉ះពាល់ដល់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិច ដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ចំនួន ៩ករណី ស្មើរនឹង ៣,៤៥២.០០ គ្រួសារ។ ក្រុមហ៊ុនទាំងនោះមានដូចជា ក្រុមហ៊ុនហ្គូជីសាន់ ក្រុមហ៊ុនដីធីស៊ី (DTC Company) ក្រុមហ៊ុនសុខឃ្វីន (Sofin KCD) ក្រុមហ៊ុនរិទ្ធីគិរីសីមា ក្រុមហ៊ុនLKL ក្រុមហ៊ុនហួរលីន ក្រុមហ៊ុនវិឡាអភិវឌ្ឍន៍ (ហៅក្រុមហ៊ុន យីមលុច្យ) ក្រុមហ៊ុនចិញភឿក ១។

ខេត្តកំពង់ស្ពឺ មានករណីវិវាទដីធ្លីប៉ះពាល់ដល់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិចដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ចំនួន ៥ករណី ស្មើរនឹង ៥៨១គ្រួសារ។ ក្រុមហ៊ុនទាំងនោះមានដូចជា ក្រុមហ៊ុនភ្នំពេញស៊ូហ្គ័រ(Phnom Penh Sugar) ក្រុមហ៊ុនHLH ក្រុមហ៊ុនស៊ីធីម៉ាត(CT Mart)។

ខេត្តព្រះវិហារ មានករណីវិវាទដីធ្លីប៉ះពាល់ដល់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិចដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ចំនួន ៣ករណី ស្មើរនឹង ១,៥៦៧.០០ គ្រួសារ។ ក្រុមហ៊ុនទាំងនោះមានដូចជា ក្រុមហ៊ុនហេងយូ (Heng You Cambodia Company) ក្រុមហ៊ុនឡាន ហ្វេង និងក្រុមហ៊ុនរុយហ្វេង ក្រុមហ៊ុនទ្រីភាព។

ខេត្តក្រចេះ មានករណីវិវាទដីធ្លីប៉ះពាល់ដល់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិចដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ចំនួន ២ករណី ស្មើរនឹង ២៧៨គ្រួសារ។ ក្រុមហ៊ុនទាំងនោះរួមមាន ក្រុមហ៊ុនប៊ីជីមិចកូសុធីអភិវឌ្ឍន៍ ក្រុមហ៊ុនដូទីសាយហ្គន ចិញហៀក។ ចំណែកខេត្តពោធិ៍សាត់ មានករណីវិវាទដីធ្លីប៉ះពាល់ដល់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិចដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ចំនួន ១ករណី ស្មើរនឹង

២៣គ្រួសារ គឺក្រុមហ៊ុន អ៊ឹមឌីអេសថ្មដារ(MDS Import Export Co.,Ltd./ MDS Thmar Dar SEZ)។

១១. ការផ្លាស់ទីកន្លែងដោយបង្ខំ

ប្រពលជារដ្ឋរងគ្រោះនៃវិវាទដីធ្លីនៅក្នុងករណីធ្ងន់ធ្ងរមួយចំនួនត្រូវបានប្តូរទៅឲ្យរស់នៅ ឬ ប្រើប្រាស់និងអាស្រ័យផលនៅទីតាំងថ្មី ដែលពេលខ្លះទីតាំងថ្មីទាំងនោះនៅមិនទាន់បានរៀបចំហេដ្ឋារចនាសម្ព័ន្ធ ឬ ការប្រកបមុខរបរដាំដុះសម្រាប់បំរើសេចក្តីត្រូវការរបស់ពួកគាត់ទាំងស្រុងនៅឡើយ។ ជាក់ស្តែងនៅក្នុងចំណោមវិវាទទាំង ៣១៤ករណី ដែលកំពុងរងចាំដំណោះស្រាយ មានវិវាចំនួន ៥៨ករណី នាឆ្នាំកន្លងមកប្រជាពលរដ្ឋរងគ្រោះត្រូវបានប្តូរចេញពីទីតាំងមានវិវាទឲ្យទៅរស់នៅ ឬប្រើប្រាស់នឹងអាស្រ័យផលនៅទីតាំងថ្មី។ វិវាទទាំងនោះកើតមាននៅក្នុងរាជធានីភ្នំពេញ និងខេត្តព្រះវិហារ មាន១២ករណី ខេត្តព្រះសីហនុ មាន៦ករណី ខេត្តមណ្ឌលគិរី និង ខេត្តពោធិ៍សាត មាន៥ករណី ខេត្តបន្ទាយមានជ័យ មាន៣ករណី។ ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តក្រចេះ និងខេត្តឧត្តរមានជ័យ និងខេត្តរតនគិរី មាន២ករណី។ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តប៉ៃលិន និងខេត្តតាកែវ មាន ១ករណី។



រូបទី២១៖ ចំនួនវិវាទបង្កឲ្យមានការប្តូរប្រជាពលរដ្ឋរងគ្រោះទៅទីតាំងថ្មី

វិវាទទាំង ៥៨ករណីនេះប៉ះពាល់ដល់ប្រជាពលរដ្ឋ ចំនួន ១១,៨៦៣.០០ គ្រួសារ ដោយករណីប៉ះពាល់ប្រជាពលរដ្ឋធំបំផុតមានចំនួន ១,១៦៣.០០ គ្រួសារ ស្ថិតក្នុងឃុំចំនួន៤ នៃស្រុកបូទុមសាគរ និងស្រុកគិរីសាគរ ជាមួយក្រុមហ៊ុនឯកជនមួយមានឈ្មោះថា ក្រុមហ៊ុន Union Development Group ជាក្រុមហ៊ុន ដើម្បីអភិវឌ្ឍជាទេសចរណ៍ធម្មជាតិក្នុងខេត្តកោះកុង ដែលទទួលបានសិទ្ធអភិវឌ្ឍន៍តាមរយៈកិច្ចសន្យាជួលរយៈពេលវែងក្នុងឆ្នាំ ២០០៨។ វិវាទនេះកើតឡើងនៅក្នុងឆ្នាំ២០១០ លើផ្ទៃដីទំហំ ៥៥,១០០.០០ ហិកតា ជាប្រភេទដីលំនៅឋាន ដីចំការ និងដីស្រែ ដោយកន្លងមកធ្លាប់បង្កឲ្យមានអំពើរហឹង្សារ ការគំរាមកំហែងពីភាគីក្រុមហ៊ុនមកលើប្រជាពលរដ្ឋរងគ្រោះទៀតផង។ នៅក្នុងការដោះស្រាយដោយអន្លើរៗកន្លងមក ភាគីក្រុមហ៊ុនបានផ្តល់ទីតាំងថ្មីសម្រាប់ប្រជាពលរដ្ឋរងគ្រោះ ហើយមានប្រជាពលរដ្ឋ ១,០០០.០០គ្រួសារ យល់ព្រមចាកចេញទៅរស់នៅទីតាំងថ្មី ហើយក្នុងឆ្នាំ ២០១៦ គ្រួសារពលរដ្ឋទាំងនោះបានទទួលប័ណ្ណកម្មសិទ្ធិនៅលើដីទីតាំងថ្មីនោះ ប៉ុន្តែមានប្រជាពលរដ្ឋ ១៨៣ក្នុងចំណោម ១,០០០.០០គ្រួសារ បានធ្វើការតវ៉ាចំពោះការផ្តល់សំណងកន្លងមក ដោយទាមទារនូងសំណងបន្ថែម គឺក្នុងមួយគ្រួសារ ថវិការចំនួន ២,០០០.០០ ដុល្លាអាមេរិច និងដីទំហំ ២.៥ ហិកតា។ ចំពោះប្រជាពលរដ្ឋដែលនៅសេសសល់មួយចំនួនទៀត ទាមទារឲ្យធ្វើការកាត់ឆ្វៀលដីរបស់ពួកគាត់ចេញពីប្លង់របស់ក្រុមហ៊ុន។ ករណីវិវាទដែលដោះមិនចេះចប់នេះនៅតែបន្តរហូត គិតចាប់តាំងពីពេលមានវិវាទរហូតមកដល់បច្ចុប្បន្នមានរយៈពេល ៦ឆ្នាំមកហើយ។

ជាមួយគ្នានេះមានការសិក្សាស្រាវជ្រាវជាច្រើនបានធ្វើឡើងពាក់ព័ន្ធនឹងការផ្លាស់ប្តូរទីតាំងថ្មីរបស់ក្រុមហ៊ុន Union Development Group សម្រាប់ប្រជាពលរដ្ឋរងគ្រោះ។ ជាក់ស្តែងការសិក្សាស្រាវជ្រាវមួយដែលបានធ្វើឡើងក្នុងឆ្នាំ ២០១៥ បានរកឃើញនូវភាពខ្វះខាត ក៏ដូចគ្នាការមិនបានយកចិត្តទុកដាក់ចំពោះនិតិវិធីនៃការ

រៀបចំទីតាំងថ្មីសម្រាប់ប្រជាពលរដ្ឋរងគ្រោះជាច្រើន។ មួយក្នុងចំណោមការរកឃើញនោះ បានលើកឡើងថាការកំណត់ទីតាំងថ្មីមិនមានការចូលរួមជាសាធារណៈឬការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរងផលបះពាល់មុននឹងធ្វើការប្តូរទីតាំង។ ប្រជាពលរដ្ឋរងគ្រោះភាគច្រើនមានការយល់ដឹងតិចតួចពីគោលនយបាយទៅលើការផ្លាស់ប្តូរទីតាំងថ្មី និងសំណងនឹងផ្តល់ជូន និងមិនមានការជូនដំណឹងជាមុន។ ការសិក្សាក៏បានរកឃើញផងដែរថា ការផ្តល់សំណងមិនគ្រប់គ្រាន់ និងការកង្វះខាតប្រសិទ្ធភាពនៃផែនការប្តូរទីតាំងបានធ្វើឲ្យចំណូលរបស់ប្រជាពលរដ្ឋមានការធ្លាក់ចុះបើប្រៀបធៀបទៅនឹងចំណូលដែលគេធ្លាប់ទទួលបាននៅភូមិតាមឆ្នេរសមុទ្ររបស់ពួកគេ នេះដោយសារមានការពិបាកក្នុងការបន្សាំខ្លួនទៅនឹងទឹកដីថ្មី។ លើពីនេះហេដ្ឋរចនាសម្ព័ន្ធនៅទីតាំងថ្មីនៅមិនទាន់អភិវឌ្ឍន៍គ្រប់គ្រាន់នៅឡើយខណៈដែលប្រជាពលរដ្ឋបានផ្លាស់ទៅរស់នៅទីនោះអស់រយៈពេលច្រើនឆ្នាំមកហើយ[15]។

វិវាទចំនួន ៥៨ករណី នាំឲ្យមានការប្តូរប្រជាពលរដ្ឋទៅរស់នៅ ឬការប្រើប្រាស់និងអាស្រ័យផលនៅទីតាំងថ្មី មានវិវាទចំនួន ១៩ករណី បង្ករដោយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដូចជាខេត្តមណ្ឌលគិរី និងខេត្តព្រះវិហារ មាន៥ករណី ខេត្តពោធិ៍សាត់ មាន៣ករណី ខេត្តកំពង់ស្ពឺ និងខេត្តរតនគិរី មាន២ករណី ខេត្តកោះកុង និងខេត្តក្រចេះ មាន១ករណី។ ក្រុមហ៊ុនទាំងនោះរួមមាន ខេត្តមណ្ឌលគិរី មានក្រុមហ៊ុន ហ្វូជីសាន់ ក្រុមហ៊ុនឌីធីសី (DTCCompany) ក្រុមហ៊ុនសុខឃ្វីន(Sofin KCD) ក្រុមហ៊ុនបិញភឿក១ និងក្រុមហ៊ុន ប៉ាស៊ីហ្វិច(Pacific) ។ ខេត្តព្រះវិហារ មានក្រុមហ៊ុនហេងយូ (Heng You Cambodia Company) ក្រុមហ៊ុនរួយហ្វេង ក្រុមហ៊ុន ឡានហ្វេង និងក្រុមហ៊ុនរួយហ្វេង ក្រុម ហ៊ុន ហ្គ្រីរ៉ាប់ប័រ(Green Rubber) និងក្រុមហ៊ុនទ្រីភាព។

---

[15] *A study on resettlement schemes of larg scale land lease to Chiness investment in Cambodia: Case study of Union Development Group Co.,Ltd*

ខេត្តពោធិ៍សាត់ មានក្រុមហ៊ុនអឹមឌីអេសថ្មរដា (MDS Import Export Co.,Ltd./ MDS Thmar Dar SEZ) ក្រុមហ៊ុន អ៊ុនខបភើរេសិន/តូច ហ៊ាវ និងក្រុមហ៊ុន រតនវិសាល។

ខេត្តកំពង់ស្ពឺ មានក្រុមហ៊ុន ហ្គោលដែនឌីវែលុបមែន(Golder Land Development Co.Ltd) និងក្រុមហ៊ុន HLH។

ខេត្តរតនគិរី មានក្រុមហ៊ុនតាយសេង/ស្វីសរ៉ាប់ប័រ និងក្រុមហ៊ុនហេងប្រាឌ័រ។ ខេត្តកោះកុង មានក្រុមហ៊ុនលីយ៉ុងជាត (SEZ Koh Kong) និងខេត្តក្រចេះ មានក្រុមហ៊ុន ប៊ីជីមុិចកូសុធីអភិវឌ្ឍន៍។

១២. បទពិសោធន៍នៃដំណោះស្រាយល្អៗ

រៀនសូត្រពីវិវាទទាំង ៥៨ករណីបានដោះស្រាយចប់ពេញលេញទាំងស្រុង និងវិវាទ ១៦៥ករណីដោះស្រាយបានមួយផ្នែកនៅក្នុងឆ្នាំ ២០១៦នេះ មានការសារទរជាច្រើនពីប្រជាពលរដ្ឋដែលទទួលបានការដោះស្រាយ ជាពិសេសជាការដោះស្រាយដោយបញ្ចប់នូវការកើតឡើងវិញជាថ្មីលើវិវាទចាស់ៗ តាមរយៈការចុះបញ្ជីក្បាលដីទំនាស់ដែលបានដោះស្រាយរួចជូនដល់ភាគីវិវាទ និងចែកជូននូវប័ណ្ណកម្មសិទ្ធិដោយផ្ទាល់ដៃ។ ជាក់ស្តែង វិវាទដីធ្លីកើតនៅក្នុងភូមិខ្នងក្រពើលិច និងភូមិខ្នងក្រពើកើត ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ រវាងប្រជាពលរដ្ឋ ៤៣៤ គ្រួសារ ជាមួយ ហ៊ុនចំការកៅស៊ូមេមត ខូអិលធីឌី តាំងពីឆ្នាំ២០០៩។ ករណីនេះបានអូសបន្លាយអស់រយៈពេលជិត១០ឆ្នាំ ទើបតែទទួលបានការដោះស្រាយក្នុងឆ្នាំនេះ តាមរយៈយុទ្ធសាស្ត្រថ្មីរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយការបង្កើតក្រុមការងារដោះស្រាយវិវាទដីធ្លីតាមបណ្តាខេត្ត បច្ចុប្បន្នប្រជាពលរដ្ឋទាំងនេះបានទទួលប័ណ្ណកម្មសិទ្ធិលើដីវិវាទតាមរយៈការចុះចែកដោយផ្ទាល់ពីតំណាងដ៏ខ្ពស់ខ្ពស់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់។

ជាមួយគ្នានេះដែរ យុទ្ធសាស្ត្រនៃការដោះស្រាយអនុវត្តដោយក្រុមការងារដោះស្រាយវិវាទនេះព្យាយាមធ្វើការដោះស្រាយក្រៅប្រព័ន្ធតុលាការ បើទោះករណីខ្លះត្រូវស្ថិតក្នុងប្រព័ន្ធតុលាការក៏ដោយ ការនេះគឺក្នុងគោលបំណងធ្វើការសម្របសម្រួលដោយគិតពីផលប្រយោជន៍របស់ប្រជាពលរដ្ឋរងគ្រោះ និងកាត់បន្ថយការចំណាយថវិការក្នុងការចំណាយលើការធ្វើដំណើរ ឬចំណាយផ្សេងៗដោយក្រុមការងារចុះទៅដោះស្រាយដោយផ្ទាល់ជាមួយប្រជាពលរដ្ឋនៅនឹងកន្លែងវិវាទ។ ការដោះស្រាយនេះ យកការសម្រមម្រួលជាធំ ដោយផ្អែកលើគោលការណ៍ច្បាប់ និងនិតិវិធី។

បន្ថែមពីនេះទៀតនាពេលថ្មីនេះ ប្រមុខរដ្ឋាភិបាលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសម្រេចបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ឲ្យអាជ្ញាធរប្រមូល និងទទួលពាក្យបណ្តឹងពីពលរដ្ឋនានា នៅទូទាំងប្រទេស ដើម្បីពិនិត្យ និងដោះស្រាយជូនពួកគេវិញ។ អនុក្រឹត្យរដ្ឋាភិបាលធ្វើឡើង មុនការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំសង្កាត់ ឆ្នាំ២០១៧ និងតំណាងរាស្ត្រឆ្នាំ២០១៨ ខាងមុខ។ តាមអនុក្រឹត្យចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិនេះ មានតួនាទីភារកិច្ចប្រមូល និងទទួលពាក្យបណ្តឹងនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬបញ្ជូនពាក្យបណ្តឹង ទាំងឡាយដែលមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន ទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បី ពិនិត្យតាមដាន និងដោះស្រាយ ឬផ្តល់ព័ត៌មានដល់ម្ចាស់ពាក្យបណ្តឹង។ យន្តការរំពឹងថារាល់ករណីវិវាទកើតមាននឹងត្រូវបានដោះស្រាយទាន់ពេលវេលានិងចំស្ថាប័នជំនាញ និងមិនរំលងករណីណាមួយដែលបានលើកឡើងនោះឡើយ។

១១. សេចក្តីសន្និដ្ឋាន

<u>ករណីវិវាទដីធ្លីកើតថ្មី:</u> សម្រាប់ឆ្នាំ២០១៦ វិវាទដីធ្លីប្រចាំឆ្នាំមានចំនួន ៥៦ ករណី ចំនួននេះមានការកើនឡើងទ្វេរដងធៀបទៅនឹងវិវាទថ្មីកើតឡើងក្នុងឆ្នាំ

២០១៥ មានចំនួន ២៣ករណី។

<u>ករណីវិវាទដីធ្លីតាមបណ្តាខេត្ត:</u> នៅក្នុងខេត្តទាំង ២៤ខេត្ត និងរាជធានីភ្នំពេញ ខេត្តរតនគិរី មានវិវាទដីធ្លីច្រើនជាងគេ មានចំនួន ៣១ករណី បន្ទាប់មកគឺរាជធានីភ្នំពេញ មានវិវាទចំនួន ២៩ករណី។

<u>ករណីវិវាទដីធ្លីដោះស្រាយចប់ពេញលេញទាំងស្រុងក្នុងឆ្នាំ២០១៦៖</u> មានករណីវិវាទចំនួន ៥៨ករណី បានដោះស្រាយចប់ពេញលេញទាំងស្រុង។ ចំនួននេះមានការកើនឡើងទ្វេដងបើធៀបទៅនឹងតួរលេខនៅឆ្នាំ២០១៥ មានចំនួន ២១ករណី ប៉ុន្តែចំនួននេះទាបជាងវិវាទដោះស្រាយចប់ពេញលេញទាំងស្រុងក្នុងឆ្នាំ ២០១៤ មានចំនួន ៦៨ករណី ឆ្នាំ២០១៣ មានចំនួន ៨១ករណី និងឆ្នាំ២០២១២ មានចំនួន ១០៨ករណី។

<u>ស្ថាប័នទទួលពាក្យបណ្តឹង:</u> ក្នុងចំណោមវិវាទ ចំនួន ៣៨២ករណី មានបណ្តឹងសរុបចំនួន ១,០៥១.០០បណ្តឹង។ មានពាក្យបណ្តឹងចំនួន ១៤៨បណ្តឹង ដែលគួរភាគីវិវាទសម្រេចចិត្តបានដាក់ទៅប្រព័ន្ធតុលាការ និង បណ្តឹងចំនួន ៩០៣បណ្តឹង បានដាក់ទៅស្ថានប័នក្រៅប្រព័ន្ធតុលាការ។

<u>ស្ថាប័នបានដោះស្រាយវិវាទដីធ្លីឆ្នាំ២០១៦៖</u> ក្នុងចំណោមវិវាទ ៥៨ករណី បានដោះស្រាយចប់ពេញលេញទាំងស្រុងក្នុងឆ្នាំ២០១៦ មានស្ថានប័នជាច្រើនដែលបានធ្វើការដោះស្រាយក្នុងនោះមាន សាលាខេត្ត ដោះស្រាយបានចំនួន១៣ករណី អាជ្ញាធរមូលដ្ឋានឃុំនិងស្រុក ដោះស្រាយបានចំនួន១២ករណី ក្រុមការងារខេត្ត និងមន្ទីរពាក់ព័ន្ធ ដោះស្រាយបានចំនួន៨ករណី រាជរដ្ឋាភិបាល ដោះស្រាយបានចំនួន៥ករណី។ តុលាការ និងគួរភាគីនៃវិវាទ ដោះស្រាយបានចំនួន៤ករណីដូចគ្នា។ គណៈកម្មការសុរិយោដី ដោះស្រាយបានចំនួន៣ករណី មន្ទីរបរិស្ថាន ដោះស្រាយបានចំនួន២ករណី។ ទីស្តីការគណៈរដ្ឋមន្ត្រី ការបញ្ចប់ដោយចុងចម្លើយនិងដើមបណ្តឹង

ស្លាប់ទាំងអស់ មន្ទីរសុរិយោដីខេត្ត រដ្ឋបាលព្រៃឈើ ក្រសួងរៀបចំដែនដី និងព្រះបរមរាជវាំង ដោះយស្រាយបានចំនួន១ករណីដូចគ្នា ហើយករណីវិវាទចំនួន២មិនមានព័ត៌មានពីស្ថាប័នដោះស្រាយ។

គួរកត់សម្គាល់ នៅក្នុងចំណោមវិវាទទាំង ៥៨ករណី បានដោះស្រាយចប់ពេញលេញទាំងស្រុងនេះ មានវិវាទ ចំនួន១៥ករណីបានដាក់ពាក្យបណ្តឹងទៅស្ថាប័នតុលាការ ប៉ុន្តែមានតែវិវាទចំនួន ៤ករណីប៉ុណ្ណោះដោះស្រាយបញ្ចប់ដោយប្រព័ន្ធតុលាការ។ ចំណែកវិវាទ ១១ករណី ក្នុងចំណោមវិវាទទាំង ១៥ករណីនេះដោះស្រាយដោយ ស្ថាប័នផ្សេងៗដូចជា រាជរដ្ឋាភិបាល ទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មាការជាតិដោះស្រាយវិវាទដីធ្លីអាជ្ញាធរខេត្ត អភិបាលស្រុក អាជ្ញាធរឃុំ ការសម្រប់សម្រួលដោយអង្គការ Adhoc គួរភាគីវិវាទសម្របសម្រួលគ្នាបញ្ចប់ជម្លោះ។

<u>គ្រួសាររងផលប៉ះពាល់ពីវិវាទដីធ្លី:</u> វិវាទដីធ្លីចំនួន ៣១៤ករណី កំពុងបន្តរងចាំដំណោះស្រាយ បានប៉ះពាល់ដល់ប្រជាពលរដ្ឋ ចំនួន ៥៤,៥០៧.០០គ្រួសារ។ ខេត្តឧត្តរមានជ័យមានប្រជាពលរដ្ឋរងផលប៉ះពាល់ពីវិវាទដីធ្លីច្រើនជាងគេ មានចំនួន ៦,៧៩០.០០ គ្រួសារ នេះបណ្តាលមកពីវិវាទភាគច្រើនជាវិវាទកើតឡើងក្នុងសហគមន៍ព្រៃឈើដែលមានសមាជិកសហគមន៍ច្រើន។ បន្ទាប់ គឺរាជធានីភ្នំពេញមានប្រជាពលរដ្ឋចំនួន ៤,៨៩៣.០០គ្រួសារ រងផលប៉ះពាល់ពីវិវាទចំនួន ២៩ករណី។

<u>ប្រភេទដីដែលរងផលប៉ះពាល់ពីវិវាទដីធ្លី:</u> វិវាទដីធ្លីទាំង ៣១៤ករណីប៉ះពាល់លើផ្ទៃដីទំហំ ១,០៥២,៩៣៥.៩១ហិកតា។ ដីចំការគឺជាប្រភេទដីដែលរងផលប៉ះពាល់វិវាទច្រើនជាងគេ ដោយមានវិវាទចំនួន ១៤៩ករណីកើតឡើងលើដីប្រភេទនេះ បន្ទាប់គឺដីភូមិ/ដីលំនៅឋាន មានវិវាទចំនួន ១០៨ករណី។

<u>មូលហេតុនៃវិវាទដីធ្លី:</u> មូលហេតុធំៗ ដែលបង្កឲ្យមានវិវាទដីធ្លី នៅក្នុង

ប្រទេសកម្ពុជាគឺ មានបីសំខាន់ៗគឺ ការផ្តល់ដីសម្បទានដីសេដ្ឋកិច្ចនាពេលកន្លងមក ការប្រើប្រាស់អំណាចជាមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធនិងអំណាចងារជាឧកញ្ញ៉ា/អ្នកមាន និងការរំលោភយកដីរដ្ឋធ្វើជាកម្មសិទ្ធិ។

<u>ឯកសារប្រើប្រាស់ដោយគូរភាគីវិវាទក្នុងការទទួលបានដី:</u> មានឯកសារជាច្រើនប្រើប្រាស់ជាសំអាងក្នុងការបញ្ជាក់ពីភាពជាម្ចាស់ទៅលើដីវិវាទ ឯកសារទាំងនោះមានទាំងឯកសារផ្លូវច្បាប់ និងស្ថានភាពកាន់កាប់ជាក់ស្តែង។ ការសំអាងលើកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ចមានច្រើនជាងគេ មានវិវាទចំនួន ៨៤ករណី បន្ទាប់គឺការសំអាងការកាន់កាប់/រស់នៅនិងអាស្រ័យផលជាក់ស្តែង មាន៥២ករណី និងការសំអាងលើលិខិតទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន ៤៣ករណី។

<u>ការកាន់កាប់បច្ចុប្បន្នលើដីមានវិវាទ:</u> ក្នុងចំនោមវិវាទ ៣១៤ករណី មានវិវាទដីធ្លីចំនួន ១០១ករណីស្មើរនឹង៣៥.០៣ភាគរយ កំពុងប្រើប្រាស់ដោយភាគីចុងបណ្តឹងវិវាទ ចំនួន ៨៤ករណីស្មើរនឹង២៦.៧៥ភាគរយនៃវិវាទចំនួន ដែលកំពុងកើតមាន និងរងចាំការដោះស្រាយ កំពុងប្រើប្រាស់ដោយដើមបណ្តឹង វិវាទចំនួន ៥៣ករណីស្មើរ ១៦.៨៧ភាគរយ កំពុងប្រើប្រាស់ដោយភាគីទាំងសងខាង ហើយវិវាទចំនួន ៦៧ ករណីស្មើរនឹង២១.៣៣ភាគរយ។

<u>វិវាទដែលបង្ករផលប៉ះពាល់លើជនជាតិដើមភាគតិច:</u> ក្នុងចំណោមវិវាទ ៣១៤ករណី មានវិវាទ ៤៤ករណី ស្មើរនឹង១៣.៦៩ភាគរយ កំពុងបន្ត ប៉ះពាល់ដល់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិច នៅក្នុងខេត្តចំនួន៧ មានដូចជា ខេត្តរតនគិរី មាន២០ករណី ខេត្តមណ្ឌលគិរី មាន១១ករណី ខេត្តកំពង់ស្ពឺ មាន៥ករណី ខេត្តព្រះវិហារ មាន៤ករណី ខេត្តក្រចេះ មាន២ករណី ខេត្តកោះកុង១៦ និងខេត្តពោធិ៍សាត់ មាន១ករណីដូចគ្នា។ វិវាទទាំងនេះ ប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ៩,៤០៦.០០ គ្រួសារ លើផ្ទៃដី ៥៥,៣២៤.៥១ ហិកតា។

<u>ការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ:</u> ក្នុងចំណោមវិវាទទាំង ៣១៤ករណី ដែល

កំពុងរងចាំដំណោះស្រាយ មានវិវាចំនួន ៥៨ករណី នាឆ្នាំកន្លងមកប្រជាពលរដ្ឋរងគ្រោះត្រូវបានប្តូរចេញពីទីតាំងមានវិវាទឲ្យទៅរស់នៅ ឬប្រើប្រាស់និងអាស្រ័យផលនៅទីតាំងថ្មី ។

<u>បទពិសោធន៍នៃដំណោះស្រាយល្អ។៖</u> ការដោះស្រាយដោយបញ្ឈប់នូវការកើតឡើងវិញជាថ្មីលើវិវាទចាស់ៗ តាមរយៈការចុះបញ្ជីក្បាលទំនាស់ដែលបានដោះស្រាយរួចជូនដល់ភាគីវិវាទ និងចែកជូននូវប័ណ្ណកម្មសិទ្ធិដោយផ្ទាល់ ជាយុទ្ធសាស្ត្រថ្មីរបស់ រដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធក្នុងការដោះស្រាយ ។

យុទ្ធសាស្ត្រមួយទៀតគឺការដោះស្រាយអនុវត្តដោយក្រុមការងារដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ ដោយយកការសម្រមម្រួលជាធំ ដោយផ្អែកលើគោលការណ៍ច្បាប់ និងនិតិវិធី។

ឧបសម្ព័ន្ធ

ករណីវិវាទដែលបានដោះស្រាយចប់ពេញលេញទាំងស្រុងក្នុងឆ្នាំ ២០១៦

ID	Province	District	Commune	Village	StatusResolution
2434	Banteay Meanchey	Malai	Tuol Pongro	Santepheap	Resolved for complainant
2143	Kampong Cham	Stueng Trang	Areaks Tnaot	Baek Anlung	Resolved for defendant
2147	Kampong Cham	Memot	Tramung		Resolved for complainant
2309	Kampong Cham	Prey Chhor	Thma Pun	Andoung Phdau	Resolved by compensation
2660	Kampong Cham	Batheay	Tumnob	Prayuk	Resolved for complainant
2713	Kampong Cham	Kampong Siem	Krala	Angkuonh Dei	Resolved for complainant
2875	Kampong Cham	Tboung Khmum	Sralab		Resolved for complainant
2443	Kampong Chhnang	Rolea B'ier	Rolea B'ier	Trapeang Trach	Resolved for defendant
2936	Kampong Chhnang	Baribour	Pech Changvar	Tang Thnuem	Resolved by compensation
2940	Kampong Chhnang	Baribour	Anhchanh Rung		Resolved for complainant
2200	Kampong Thom	Santuk	Kraya	Thma Samlieng	Resolved for complainant
2306	Kampong Thom	Santuk	Kakaoh	Sala Santuk	Resolved for defendant
2851	Kampong Thom	Stoung	Samprouch	Slak Kranh	Resolved for both complainant and defendant
2852	Kampong Thom	Kampong Svay			Resolved for complainant
2946	Kampong Thom	Baray	Baray	11 តូចិ	Resolved for complainant

2948	Kampong Thom	Sandan	Mean Ritth		Resolved for complainant
2953	Kampong Thom	Santuk	Kraya	Thma Samlieng	Resolved for complainant
2785	Kampot	Toek Chhou	Preak Tnoat	Praek Kreang Trapeang Ropov	Resolved for defendant
2796	Kampot	Kampong Trach	Ruessei Srok Khang Lech	Thkov	Resolved for complainant
2956	Kampot	Kampong Trach	Boeng Sala Khang Tboung	Kaoh Chamkar	Resolved for complainant
2611	Kandal	Mukh Kampul	Sambuor Meas	Poung	Resolved by compensation
514	Koh Kong	Mondol Seima	Bak Khlang	Neang Kok	Resolved for complainant
2593	Koh Kong	Kiri Sakor	Kaoh Sdach	Peam Kay	Resolved for complainant
2962	Kracheh	Preaek Prasab	Saob		Resolved for complainant
2829	Krong Pailin	Sala Krau	Stueng Trang	Tumnob	Resolved for defendant
2839	Krong Pailin	Pailin	Ou Tavau		Resolved for defendant
